ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ

## ចក្ខុវិស័យឆ្នាំ ២០៣៥

រៀបចំដោយ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

បោះពុម្ពផ្សាយលើកទី១

ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤, ខែតុលា ឆ្នាំ២០២០

ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ ចក្ខុវិស័យឆ្នាំ ២០៣៥

# ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ

## ចក្ខុវិស័យឆ្នាំ២០៣៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
លេខ: ០៦០ គគរ

# សេចក្តីសម្រេច
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ រាជធានីភ្នំពេញ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
## និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍



អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

-បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ

-បានឃើញសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

-យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣៥ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសម្រេចនេះ។

**ប្រការ២.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌសែនសុខត្រូវរៀបចំផែនការសម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខាងលើ

នេះឱ្យមានប្រសិទ្ធភាព និងត្រូវរាយការណ៍អំពីវឌ្ឍនភាពជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌសែនសុខត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ ក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខមុនពេលកំណត់អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខត្រូវអនុវត្តតាមនីតិវិធីដែលមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ និងអភិបាលនៃគណៈអភិបាលខណ្ឌសែនសុខនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌសែនសុខត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៧ ៦ ១២ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ...០៧០ សសរ... ចុះថ្ងៃ...ពុធ ១២កើត...ខែ...កត្តិក...ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ត្រូវនឹងថ្ងៃទី...២៨... ខែ...តុលា... ឆ្នាំ២០២០

ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ រាជធានីភ្នំពេញ

# ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ

## ចក្ខុវិស័យឆ្នាំ២០៣៥

## មាតិកា

ទំព័រ


**១-សេចក្តីផ្តើម** ........ ១

**២-ក្របខណ្ឌសេដ្ឋកិច្ច សង្គម និងចក្ខុវិស័យខណ្ឌសែនសុខ** ........ ២

២.១- ក្របខណ្ឌសេដ្ឋកិច្ច សង្គម ........ ២

២.២- ចក្ខុវិស័យ ........ ៣

**៣-គោលបំណងនិងគោលដៅនៃប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ** ........ ៣

៣.១- គោលបំណង ........ ៤

៣.២- គោលដៅ ........ ៤

**៤-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សខណ្ឌសែនសុខប្រកបដោយភាពឆ្លាតវៃ ចីរភាព និងបរិយាបន្ន** ........ ៤

៤.១- ការអភិវឌ្ឍខណ្ឌនិងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាពនិងចីរភាព ........ ៤

៤.១.១- តំបន់នគរូបនីយកម្មខណ្ឌបច្ចុប្បន្ន ........ ៥

៤.១.២- ទិសដៅនគរូបនីយកម្ម ........ ៥

៤.១.៣- យុទ្ធសាស្ត្រអភិវឌ្ឍខណ្ឌឆ្លាតវៃ ចីរភាព និងបរិយាបន្ន ........ ៦

៤.២- យុទ្ធសាស្ត្រគ្រប់គ្រងនិងប្រើប្រាស់ដី ........ ៨

៤.២.១- ប្រភេទដីអាចសាងសង់បាន ........ ៨

៤.២.២- ប្រភេទដីកម្រិតការសាងសង់ ........ ១០

៤.៣- យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ........ ១១

៤.៣.១- ផ្លូវថ្នល់និងផ្លូវរថភ្លើង ........ ១១

៤.៣.២- ផ្លូវទឹក ........ ១១

៤.៣.៣- ផ្លូវអាកាស ........ ១២

៤.៣.៤- ថាមពលអគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ........ ១២

៤.៣.៥- ហេដ្ឋារចនាសម្ព័ន្ធសង្គមនិងវប្បធម៌ ........ ១២

៤.៣.៦- ការផ្គត់ផ្គង់ទឹកស្អាត ........ ១៣

៤.៤- យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច ........ ១៣

៤.៤.១- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ ........ ១៣

៤.៤.២- យុទ្ធសាស្ត្រគាំទ្រការអភិវឌ្ឍវិស័យកសិកម្មនិងផ្សព្វផ្សាយផលិតផលក្នុងស្រុក ........ ១៤

៤.៤.៣- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យឧស្សាហកម្មនិងសេវាកម្ម ........ ១៥

៤.៤.៤- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យពាណិជ្ជកម្មនិងធុរកិច្ច ........ ១៥

៤.៥- យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ចនិងវប្បធម៌ ........ ១៦

៤.៦- យុទ្ធសាស្ត្រការពារបរិស្ថាន ធនធានធម្មជាតិ និងគ្រប់គ្រងសំណល់.......... ១៦

៤.៦.១- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង.......... ១៦

៤.៦.២- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ.......... ១៧

៤.៦.៣- ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន.......... ១៧

៤.៦.៤- វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ.......... ១៧

៤.៧- យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ.......... ១៨

៤.៨- យុទ្ធសាស្ត្រពង្រឹងអភិបាលកិច្ចល្អ គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន.......... ១៨

**៥- ផែនការសកម្មភាព.......... ១៨**

៥.១- ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម.......... ១៩

៥.២- ការផ្សព្វផ្សាយ.......... ១៩

៥.៣- ការអនុវត្តគម្រោងតាមវិស័យ.......... ១៩

៥.៣.១- ការអភិវឌ្ឍខណ្ឌ.......... ១៩

៥.៣.២- ការអភិវឌ្ឍទេសចរណ៍.......... ១៩

៥.៣.៣- ការអភិវឌ្ឍការដឹកជញ្ជូន.......... ២០

៥.៣.៤- ការពង្រឹងកសិកម្ម សិប្បកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក.......... ២០

៥.៣.៥- ការគ្រប់គ្រងពាណិជ្ជកម្ម.......... ២០

៥.៣.៦- ការគ្រប់គ្រងបរិស្ថាន.......... ២០

៥.៣.៧- ការផ្គត់ផ្គង់ទឹកស្អាតនិងធនធានទឹក.......... ២០

៥.៣.៨- ការផ្គត់ផ្គង់ថាមពលអគ្គិសនីនិងទូរគមនាគមន៍.......... ២១

៥.៣.៩- ការគ្រប់គ្រងសំណល់រឹង.......... ២១

៥.៣.១០- ការគ្រប់គ្រងសំណល់រាវនិងប្រព័ន្ធលូបង្ហូរទឹកភ្លៀង.......... ២១

៥.៤- ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង.......... ២១

៥.៤.១- ការអនុវត្តរយៈពេលខ្លី.......... ២១

៥.៤.២- ការអនុវត្តរយៈពេលមធ្យម.......... ២១

៥.៤.៣- ការអនុវត្តរយៈពេលវែង.......... ២១

៥.៥- គម្រោងអាទិភាព.......... ២២

**៦- ធនធានហិរញ្ញវត្ថុ.......... ២២**

**៧- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ.......... ២២**

៧.១- យន្តការ.......... ២២

៧.២- ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត.......... ២៣

៧.៣- ភារកិច្ច នីតិវិធី និងគោលការណ៍.......... ២៣

៨-សេចក្តីសន្និដ្ឋាន ........................................ ២៤
អនុសាសន៍ ........................................ ២៥
សន្ទានុក្រម ........................................ ២៦
ឯកសារឧបសម្ព័ន្ធ ........................................ ៣៧

## ១-សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្សនៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែកនិងគ្រប់វិស័យក្នុងគោលដៅបង្កើននិងកែលម្អការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្រ្តចតុកោណនិងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថាដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្រ្តរៀបចំដែនដីនិងការធ្វើឱ្យប្រសើរនូវវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្រ្តនីមួយៗ។

ខណ្ឌសែនសុខជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤ របស់រាជធានីភ្នំពេញត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៩ ដោយកាត់យកសង្កាត់ចំនួន៣ពីខណ្ឌឫស្សីកែវគឺសង្កាត់ភ្នំពេញថ្មី សង្កាត់ទឹកថ្លា និងសង្កាត់ឃ្មួញ។ យោងព្រះរាជក្រឹត្យលេខ នស/រកត/០៩១០/៧៦៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញនិងខេត្តកណ្តាលបានកាត់យកឃុំចំនួន២០ពីខេត្តកណ្តាលមកបញ្ចូលក្នុងរាជធានីភ្នំពេញក្នុងនោះមានឃុំចំនួន៣គឺឃុំព្រែកព្នៅ ឃុំសំរោង និងឃុំពញាពន់ពីស្រុកពញាឮ ខេត្តកណ្តាលត្រូវបានបញ្ចូលមកក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ។ យោងអនុក្រឹត្យលេខ៥៧៨ អនក្រ.បក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតខណ្ឌព្រែកព្នៅបានកាត់យកសង្កាត់ចំនួន៣ គឺសង្កាត់ព្រែកព្នៅ សង្កាត់សំរោង និងសង្កាត់ពញាពន់ពីខណ្ឌសែនសុខ និងសង្កាត់ចំនួន២ គឺសង្កាត់គោករកានិងសង្កាត់ពន្លាំងពីខណ្ឌពោធិ៍សែនជ័យ។

បច្ចុប្បន្នខណ្ឌសែនសុខមានព្រំប្រទល់ផ្នែកខាងជើងជាប់នឹងខណ្ឌព្រែកព្នៅ ផ្នែកខាងត្បូងជាប់នឹងខណ្ឌមានជ័យ ផ្នែកខាងលិចជាប់នឹងខណ្ឌពោធិ៍សែនជ័យ និងផ្នែកខាងកើតជាប់នឹងខណ្ឌឫស្សីកែវនិងខណ្ឌទួលគោក និងមានផ្ទៃដីប្រមាណ៥ ០៧៣,៥១ហិកតា ព្រមទាំងមានចំនួន៦សង្កាត់និងមានចំនួន៤៧ភូមិគឺ៖

- សង្កាត់ភ្នំពេញថ្មីមានលេខកូដ 120801 និងមានភូមិចំនួន៦ គឺភូមិពោងពាយ ភូមិបាយ៉ាប ភូមិភ្នំពេញថ្មី ភូមិទំនប់ ភូមិទំនប់១ និងភូមិឧកញ៉ាភឹង
- សង្កាត់ទឹកថ្លាមានលេខកូដ 120802 និងមានភូមិចំនួន៧ គឺភូមិផ្សារទឹកថ្លា ភូមិសេប៉េសេ ភូមិបុរី១០០ខ្នង ភូមិចុងថ្នល់ខាងកើត ភូមិចុងថ្នល់ខាងលិច ភូមិទឹកថ្លា និងភូមិបុរីកម្មករ
- សង្កាត់ឃ្មួញមានលេខកូដ 120803 និងមានភូមិចំនួន១៣ គឺភូមិឃ្មួញ ភូមិបន្លាស្អិត ភូមិសំរោង ភូមិអន្លង់ក្ងាន ភូមិត្រពាំងរាំង ភូមិសែនសុខទី១ ភូមិសែនសុខទី២ ភូមិសែនសុខទី៣ ភូមិសែនសុខទី៤ ភូមិសែនសុខទី៥ ភូមិសែនសុខទី៦ ភូមិសែនសុខទី៧ និងភូមិត្រពាំងរាំងថ្មី

- សង្កាត់ក្រាំងធ្នង់មានលេខកូដ 120804 និងមានភូមិចំនួន៨ គឺភូមិក្រាំងអង្រ្កង ភូមិក្រាំងធ្នង់ ភូមិជាងទង ភូមិត្រពាំងជើងស្រុក ភូមិព្រៃខ្លា ភូមិសំរោងទាវ ភូមិព្រៃមូល និងភូមិវិមានទ្រង់
- សង្កាត់អូរបែកក្អមមានលេខកូដ 120805 និងមានភូមិចំនួន៥ គឺភូមិអូរបែកក្អម ភូមិត្រពាំងឈូក ភូមិអំរតីដេ ភូមិស្លែងរលើង និងភូមិទ្រុងមាន់
- សង្កាត់គោកឃ្លាងមានលេខកូដ 120806 និងមានភូមិចំនួន៨ គឺភូមិរោងចក្រ ភូមិរោងចក្រ១ ភូមិក្រុងថ្មី ភូមិត្រពាំងស្វាយ ភូមិដីថ្មី ភូមិដំណាក់ ភូមិគោកឃ្លាង និងភូមិច្រេស។

ក្នុងគោលដៅធានាការគ្រប់គ្រងនិងការអភិវឌ្ឍខណ្ឌសែនសុខប្រកបដោយចីរភាព គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌសែនសុខ ក្រោមការគាំទ្របច្ចេកទេសដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំនូវប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខចក្ខុវិស័យឆ្នាំ២០៣៥ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងនិងតម្រង់ទិសអភិវឌ្ឍដែនដីខណ្ឌសែនសុខទាំងមូលស្របតាមចក្ខុវិស័យគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀត។

ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខត្រូវបានកសាងដោយមានការសិក្សាច្បាស់លាស់លើកត្តាភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ទេសចរណ៍ និងវប្បធម៌ ព្រមទាំងគោលនយោបាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្មមានជាអាទិ៍ច្បាប់ភូមិបាល ច្បាប់ស្តីពីសំណង់ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

## ២-ក្របខណ្ឌសេដ្ឋកិច្ច សង្គម និងចក្ខុវិស័យខណ្ឌសែនសុខ

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខមានលក្ខណៈទូលំទូលាយគ្របដណ្តប់ទាំងទិដ្ឋភាពគតិយុត្តនិងបច្ចេកទេសសម្រាប់ធ្វើការសម្របសម្រួលរវាងវិស័យនានាដែលជាកម្លាំងចលករសេដ្ឋកិច្ចសំដៅធ្វើការតម្រង់ទិសការអភិវឌ្ឍនគរូបនីយកម្មប្រកបដោយចីរភាពនិងបរិយាបន្ន ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ តម្រូវការប្រើប្រាស់ដី ការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍគ្រប់វិស័យក្នុងពេលបច្ចុប្បន្ននិងទៅអនាគតដោយធានាបាននូវការការពារធនធានដី ធនធានទឹក ទឹកក្រោមដី ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិដែលអាចធ្វើការអភិវឌ្ឍឱ្យមានសណ្តាប់ធ្នាប់ របៀបរៀបរយ សោភ័ណភាព ចីរភាព និងចូលរួមបង្ការទប់ស្កាត់ការប្រែប្រួលអាកាសធាតុដូចជាការបំភាយឧស្ម័នផ្ទះកញ្ចក់ ការកើនឡើងនៃកម្តៅ ទឹកជំនន់ និងខ្យល់ព្យុះក្នុងរាជធានីជាដើម។

### ២.១-ក្របខណ្ឌសេដ្ឋកិច្ច សង្គម

ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខត្រូវបានរៀបចំឡើងដោយបានសិក្សា ប្រមូលនិងវិភាគទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គម ទិន្នន័យបរិស្ថាន ទិន្នន័យប្រជាសាស្ត្រ និងការស្រង់មតិសមស្របតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីដីធ្លី ច្បាប់ស្តីពីសំណង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

ដើម្បីកំណត់ចក្ខុវិស័យប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខដល់ឆ្នាំ២០៣៥ ក្របខណ្ឌសេដ្ឋកិច្ចសង្គម ត្រូវបានសិក្សាវិភាគតាមបែបវិទ្យាសាស្ត្រដោយផ្អែកតាមរបាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយនៃជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ និងឆ្នាំ២០១៩ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ តាមរយៈការសិក្សាខាងលើនេះ ខណ្ឌសែនសុខមានផ្ទៃដីប្រមាណ៥ ០៧៣,៥១ហិកតា ប្រជាជននៅឆ្នាំ២០០៨ មានចំនួន ១២៥ ៥៣៦នាក់ នៅឆ្នាំ២០១៨ មានចំនួន១៧១ ៨៧៤នាក់ និងនៅឆ្នាំ២០១៩ មានចំនួន១៨១ ៤១៨នាក់ ហើយតាមការព្យាករណ៍នៅឆ្នាំ២០៣៥ ប្រជាជននឹងកើនឡើងដល់៣៤៩ ១១៥នាក់ផ្អែកតាមការគណនាអត្រាកំណើនប្រចាំឆ្នាំ។ ជាមួយគ្នានេះការបែងចែកកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចសម្រាប់ខណ្ឌសែនសុខនៅឆ្នាំ២០០៨ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មមានចំនួន៣ ៣៥៤នាក់ស្មើនឹង៥,៦% វិស័យឧស្សាហកម្មមានចំនួន ២៥ ៥១៤នាក់ស្មើនឹង៤២,៩% និងវិស័យសេវាកម្មមានចំនួន៣០ ៦៧០នាក់ស្មើនឹង៥១,៥% ហើយរំពឹងថានៅឆ្នាំ២០៣៥ ប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មនឹងថយចុះមកត្រឹមចំនួន១ ២៩១នាក់ស្មើនឹង១,១% វិស័យឧស្សាហកម្មនឹងកើនឡើងដល់ចំនួន៧០ ៤០៣នាក់ស្មើនឹង៦០,០% និងវិស័យសេវាកម្មនឹងកើនឡើងដល់ចំនួន ៤៥ ៦៤៤នាក់ស្មើនឹង៣៨,៩%។

## ២.២-ចក្ខុវិស័យ

ចក្ខុវិស័យដល់ឆ្នាំ២០៣៥ គឺជំរុញគាំទ្រនិងអភិវឌ្ឍរាជធានីភ្នំពេញ “**ជាបេះដូងរបស់ព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅលើចំណុចពិសេសនៃប្រសព្វទន្លេបួនហៅថាទន្លេចតុមុខដែលជាអត្តសញ្ញាណតែមួយគ្មានពីរ និងជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងវប្បធម៌ប្រកបដោយសក្តានុពលប្រកួតប្រជែងជាមួយការអភិវឌ្ឍប្រកបដោយវឌ្ឍនភាព សមធម៌ និងចីរភាព**”។ ចក្ខុវិស័យដល់ឆ្នាំ២០៣៥ នៃប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ គឺសំដៅរៀបចំនិងអភិវឌ្ឍខណ្ឌសែនសុខជា“**តំបន់ស្នូលភាគខាងជើងនៃរាជធានីភ្នំពេញសម្រាប់រដ្ឋបាល វប្បធម៌ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍ប្រកបដោយគុណភាពបរិស្ថានរស់នៅល្អប្រសើរ សុខដុមនីយកម្ម ភាពឆ្លាតវៃ ចីរភាព និងបរិយាបន្ន**”តាមរយៈការជំរុញ៖ ១)លើកកម្ពស់ការគ្រប់គ្រង ការអភិវឌ្ឍ និងការកែលម្អនគរូបនីយកម្មនិងការគ្រប់គ្រងការប្រើប្រាស់ដីប្រកបដោយសោភ័ណភាព ប្រសិទ្ធភាព និងតុល្យភាព ២)អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារនិងសេវាទីក្រុងសម្បូរបែបប្រកបដោយគុណភាព សណ្តាប់ធ្នាប់សាធារណៈ និងធ្វើសមាហរណកម្មទៅក្នុងតំបន់ដើម្បីធានាគុណភាពរស់នៅល្អប្រសើរ ៣)ធុរកិច្ច ពាណិជ្ជកម្ម និងសេវាកម្មសម្បូរបែប ៤)លើកកម្ពស់ការគ្រប់គ្រង អភិបាលកិច្ចល្អ ការអភិវឌ្ឍសង្គម និងការផ្តល់សេវាសាធារណៈល្អ កិច្ចការពារសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈល្អ និង ៥)លើកកម្ពស់កិច្ចការពារបរិស្ថាន ថែរក្សានិងអភិរក្សបេតិកភ័ណ្ឌប្រវត្តិសាស្ត្រ និងទេសភាពធម្មជាតិ។

## ៣-គោលបំណងនិងគោលដៅនៃប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខមានគោលបំណងនិងគោលដៅដូចខាងក្រោម៖

### ៣.១-គោលបំណង

ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខមានគោលបំណងធានាការគ្រប់គ្រង និងអភិបាលកិច្ចខណ្ឌសែនសុខឱ្យមានប្រសិទ្ធភាពខ្ពស់តាមរយៈការធ្វើសមាហរណកម្មការអភិវឌ្ឍ និងការអភិរក្សនគរូបនីយកម្ម ការប្រើប្រាស់ដី និងសក្តានុពលមានស្រាប់ឱ្យបានត្រឹមត្រូវ និងចំទិសដៅប្រកបដោយភាពឆ្លាតវៃ គុណភាព តុល្យភាព ចីរភាព និងបរិយាបន្ន។

### ៣.២-គោលដៅ

ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខមានគោលដៅដូចខាងក្រោម៖

- គ្រប់គ្រងការប្រើប្រាស់ដីនិងការប្រើប្រាស់សក្តានុពលធម្មជាតិនិងនគរូបនីយកម្មស្របទៅនឹងតំបន់លំនៅឋាន ពាណិជ្ជកម្ម វប្បធម៌ នយោបាយ និងសេដ្ឋកិច្ចសង្គមប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមាហរណកម្មតាមលក្ខណៈពិសេសនៃតំបន់នីមួយៗ
- ជំរុញកំណើនសេដ្ឋកិច្ចនិងអភិវឌ្ឍធុរកិច្ចទាក់ទាញគាំទ្រដល់ការវិនិយោគសាធារណៈនិងឯកជនដើម្បីសមធម៌សង្គមនិងផ្តល់ការងារ
- លើកកម្ពស់បេតិកភ័ណ្ឌ ធនធានធម្មជាតិ កិច្ចការពារបរិស្ថាន ការអភិវឌ្ឍបៃតង និងបង្ការទប់ស្កាត់គ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព
- លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការកែលម្អ ការអភិវឌ្ឍ និងការការពារហេដ្ឋារចនាសម្ព័ន្ធ
- ធ្វើសមាហរណកម្មផែនការរូបវន្ត សេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន និងផែនការតាមវិស័យដើម្បីធានាភាពសុខដុមនីយកម្មសង្គមនិងការអភិវឌ្ឍប្រកបដោយចីរភាព
- ដោះស្រាយនិងឆ្លើយតបចំពោះសេចក្តីត្រូវការរបស់ប្រជាជនតាមរយៈអាជ្ញាធរមានសមត្ថកិច្ច។

## ៤-យុទ្ធសាស្ត្រអភិវឌ្ឍនិងអភិរក្សខណ្ឌសែនសុខប្រកបដោយភាពឆ្លាតវៃ ចីរភាព និងបរិយាបន្ន

ដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខបានកំណត់យុទ្ធសាស្ត្រគ្រប់គ្រង អភិបាលកិច្ច និងការធ្វើសមាហរណកម្មការអភិវឌ្ឍនិងការអភិរក្សប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមធម៌ដូចខាងក្រោម៖

### ៤.១-ការអភិវឌ្ឍខណ្ឌនិងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាពនិងចីរភាព

យោងច្បាប់ស្តីពីសំណង់ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១០/៧៦៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញនិងខេត្តកណ្តាល អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ អនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការបង្កើតខណ្ឌសែនសុខ នៃរាជធានីភ្នំពេញ អនុក្រឹត្យលេខ១៨១ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ២០៣៥ ខណ្ឌសែនសុខត្រូវបានកំណត់ការប្រើប្រាស់ដីជាពីរប្រភេទគឺប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់។

### ៤.១.១- តំបន់នគរូបនីយកម្មខណ្ឌបច្ចុប្បន្ន

– ជំរុញការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ
– គ្រប់គ្រង កែលម្អ និងអភិវឌ្ឍនគរូបនីយកម្មសម្រាប់ការរស់នៅប្រកបដោយផាសុកភាពនិងសោភ័ណភាពដោយរៀបចំជាគម្រោងអភិវឌ្ឍគំរូនគរូបនីយកម្មល្អតាមសង្កាត់នីមួយៗ
– បន្តការរៀបចំហេដ្ឋារចនាសម្ព័ន្ធនិងការអភិវឌ្ឍក្នុងតំបន់ដើម្បីទទួលបាននូវបរិស្ថានរស់នៅល្អប្រកបដោយសេចក្តីសុខនិងសុវត្ថិភាព
– កែលម្អនិងអភិវឌ្ឍបណ្តាញហេដ្ឋារចនាសម្ព័ន្ធរួមមានបណ្តាញផ្លូវ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី និងការប្រមូលសំណល់រឹងនិងរាវឱ្យមានលក្ខណៈសមស្របនិងមានគុណភាពដើម្បីលើកកម្ពស់គុណភាពរស់នៅនិងសោភ័ណភាពក្នុងខណ្ឌនិងរាជធានី
– កែលម្អនិងអភិវឌ្ឍផ្លូវសំខាន់ៗដូចជាមហាវិថី វិថី អនុវិថី ផ្លូវថ្មើរជើង ផ្លូវជនពិការ គន្លងផ្លូវទោចក្រយាន ចិញ្ចើមផ្លូវ ភ្លើងបំភ្លឺ ស្លាកសញ្ញាចរាចរ និងស្លាកផ្សព្វផ្សាយពាណិជ្ជកម្មនៅក្នុងខណ្ឌស្របទៅតាមតំបន់ប្រើប្រាស់ដី សោភ័ណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ និងបរិស្ថានរស់នៅប្រកបដោយសុខភាពល្អសម្រាប់មនុស្សទាំងអស់គ្នា
– រៀបចំសួនសាធារណៈដោយកំណត់ប្រភេទដើមឈើ រៀបចំសួនច្បារតាមបណ្តោយផ្លូវ ផ្លូវថ្មើរជើង សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត និងការអភិវឌ្ឍផ្ទៃបៃតងស្ថិតនៅខាងមុខនាយកដ្ឋានរុក្ខាប្រមាញ់ខាងត្បូងវត្តសំរោងអណ្តែត តាមបណ្តោយមហាវិថីមិត្តភាពភ្នំពេញ-ហាណូយ (១០១៩) ខាងមុខសាលាបឋមសិក្សាភ្នំពេញថ្មីសែនសុខ រៀបចំកែលម្អសួនតាមប្រឡាយទួលសំពៅ ប្រឡាយអូរអាគុជ ប្រឡាយមេខាងជើងរាជធានីភ្នំពេញជាប់មហាវិថីឈ្នះៗ និងកែលម្អដីចំណីមហាវិថីឈ្នះៗ
– គ្រប់គ្រងសំណង់ រៀបចំ និងកំណត់ស្ថាបត្យកម្មត្រូវមានរចនាបថខ្មែរ អត្តសញ្ញាណវប្បធម៌ខ្មែរ និងលក្ខណៈធម្មជាតិនិងបរិស្ថាន សោភ័ណភាពនិងពណ៌សមស្រប និងរបងដីឡូត៍ឱ្យមានសោភ័ណភាពល្អស្របតាមទីតាំងភូមិសាស្ត្រ មជ្ឈមណ្ឌលវប្បធម៌ នយោបាយ សន្តិសុខ និងសេដ្ឋកិច្ចសង្គម
– រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍ ការសាងសង់ និងប្លង់លម្អិតនគរូបនីយកម្មតាមសង្កាត់នីមួយៗ
– បន្តដាក់លេខផ្លូវនិងលេខផ្ទះដើម្បីងាយស្រួលក្នុងការគ្រប់គ្រងរដ្ឋបាល
– រៀបចំនិងកែលម្អតំបន់អប់រំនិងសិក្សាដូចជាសាកលវិទ្យាល័យ វិទ្យាស្ថាន សាលាវិទ្យាល័យ អនុវិទ្យាល័យ បឋមសិក្សា។

### ៤.១.២- ទិសដៅនគរូបនីយកម្ម

អភិវឌ្ឍនគរូបនីយកម្មជាតំបន់ស្នូលភាគខាងជើងនៃរាជធានីភ្នំពេញសម្រាប់រដ្ឋបាល វប្បធម៌ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍ប្រកបដោយគុណភាពបរិស្ថានរស់នៅល្អប្រសើរ សុខដុមនីយកម្ម ភាពឆ្លាតវៃ ចីរភាព និងបរិយាបន្នដោយ៖

– លើកកម្ពស់ការគ្រប់គ្រង ការអភិវឌ្ឍ និងការកែលម្អនគរូបនីយកម្មនិងការគ្រប់គ្រងការប្រើប្រាស់ដីប្រកបដោយសោភ័ណភាព ប្រសិទ្ធភាព និងតុល្យភាព
– អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាទីក្រុងសម្បូរបែបប្រកបដោយគុណភាព សណ្តាប់ធ្នាប់សាធារណៈនិងធ្វើសមាហរណកម្មទៅក្នុងតំបន់ដើម្បីធានាគុណភាពការរស់នៅល្អប្រសើរ

- និទ្ទាការនៃការអភិវឌ្ឍខណ្ឌនិងនគរូបនីយកម្មមានលទ្ធភាពពង្រីកតាមវិធីសាស្ត្រនៃការអភិវឌ្ឍបែបលាតសន្ធឹងផងនិងបញ្ឈរផង
- គ្រប់គ្រងការអភិវឌ្ឍនិងការធ្វើសមាហរណកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយប្រសិទ្ធភាពនិងចីរភាពស្របតាមបទដ្ឋានបច្ចេកទេសនគរូបនីយកម្មនិងការអភិវឌ្ឍរូបវន្តជាពិសេសបណ្តាញផ្លូវបណ្តាញអគ្គិសនី បណ្តាញទឹកស្អាត បណ្តាញលូ អាងស្តុកទឹក និងអាងប្រព្រឹត្តកម្មទឹកកខ្វក់
- ពង្រឹងសមត្ថភាពមន្ត្រីធ្វើផែនការអភិវឌ្ឍនិងគ្រប់គ្រងការអភិវឌ្ឍ ការអភិរក្ស ជាពិសេសប្រសិទ្ធភាពនៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌសែនសុខដែលមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌសែនសុខជាសេនាធិការក្នុងការគ្រប់គ្រងនិងអនុវត្តការងាររៀបចំដែនដីនិងនគរូបនីយកម្ម
- លើកកម្ពស់កិច្ចការពារបរិស្ថាន ថែរក្សា និងអភិរក្សបេតិកភ័ណ្ឌប្រវត្តិសាស្ត្រនិងទេសភាពធម្មជាតិដូចជាស្ថានីយបុរាណដ្ឋាននិងវត្តសិរីមង្គលវិនហៅវត្តឃ្មួញស្ថិតនៅភូមិឃ្មួញ សង្កាត់ឃ្មួញ និងទួលប្រាសាទបាក់ស្ថិតនៅភូមិសំរោង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ។

### ៤.១.៣- យុទ្ធសាស្ត្រអភិវឌ្ឍខណ្ឌឆ្លាតវៃ ចីរភាព និងបរិយាបន្ន

ដើម្បីលើកកម្ពស់ដល់គុណភាពរស់នៅប្រកបដោយភាពងាយស្រួលក្នុងការទំនាក់ទំនងនិងសន្សំសំចៃឆ្លើយតបទៅនឹងតម្រូវការបច្ចុប្បន្ននិងអនាគត ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ ចក្ខុវិស័យឆ្នាំ២០៣៥ បានដាក់ចេញនូវយុទ្ធសាស្ត្រអភិវឌ្ឍខណ្ឌឆ្លាតវៃតាមរយៈការគិតគូរនិងបំពាក់នូវបរិក្ខារនិងសេវាកម្មសម្រាប់ខណ្ឌឆ្លាតវៃដូចខាងក្រោមៈ

**ក-វិស័យទូរគមនាគមន៍**

ក.១-សេវាអ៊ីនធើណែតសាធារណៈ

- ផ្តល់ការប្រើប្រាស់សេវាអ៊ីនធើណែតសាធារណៈដល់សាធារណជនទូទៅនិងនៅកន្លែងសាធារណៈដូចជាស្ថាប័នរដ្ឋ សួនកម្សាន្ត តំបន់ទេសចរណ៍ តំបន់វប្បធម៌ និងមហាវិថីធំៗដែលផ្តល់ដោយស្ថាប័នផ្គត់ផ្គង់សេវាទូរគមនាគមន៍ដោយមានការគាំទ្រពីរាជរដ្ឋាភិបាល
- អនុញ្ញាតឱ្យភ្ជាប់ជាមួយនឹងឧបករណ៍ផ្សេងៗរួមទាំងទូរស័ព្ទដៃទំនើប
- រៀបចំនិងផ្សព្វផ្សាយផែនទីបង្ហាញទីតាំងដែលមានសេវាអ៊ីនធើណែតសាធារណៈ។

ក.២-មជ្ឈមណ្ឌលទិន្នន័យសាធារណៈ

- សិក្សានូវលទ្ធភាពក្នុងការកសាងមជ្ឈមណ្ឌលទិន្នន័យសម្រាប់ជំនួយគម្រោងខណ្ឌឆ្លាតវៃដែលអាចគ្រប់គ្រងនិងប្រមូលទិន្នន័យបច្ចុប្បន្នភាពក្នុងខណ្ឌ
- ជាមជ្ឈមណ្ឌលសម្រាប់ដំណើរការប្រព័ន្ធទិន្នន័យរបស់រាជរដ្ឋាភិបាលនៅក្នុងតំបន់ដែលអាចជួយសម្រួលនិងដំណើរការនូវគេហទំព័រ សេវាកម្មដល់ប្រជាពលរដ្ឋ ការងាររដ្ឋបាល និងជាប្រភពទិន្នន័យសម្រាប់ប្រព័ន្ធការងាររដ្ឋបាលអន្តរជាតិផង
- ជាមជ្ឈមណ្ឌលដែលអាចវិភាគនិងដោះស្រាយបញ្ហារបស់ខណ្ឌបានទាន់ហេតុការណ៍ផង។

ក.៣-សេវាផ្តល់សេចក្តីជូនដំណឹងពីព័ត៌មានខណ្ឌដល់ប្រជាពលរដ្ឋ

- រៀបចំប្រព័ន្ធផ្តល់ព័ត៌មានខណ្ឌដល់ប្រជាពលរដ្ឋឱ្យបានទៀងទាត់និងទាន់ហេតុការណ៍ទៅតាមប្រភេទសេចក្តីជូនដំណឹងដូចជាការធ្វើដំណើរឬចរាចរ បរិស្ថាន សេដ្ឋកិច្ច រដ្ឋបាល វប្បធម៌ សុវត្ថិភាព និងសុខមាលភាពជាដើម។

**ខ-វិស័យដឹកជញ្ជូន**

ខ.១- កសាងប្រព័ន្ធដឹកជញ្ជូនឆ្លាតវៃសាធារណៈ

- បង្កើតប្រព័ន្ធគ្រប់គ្រងចរាចរណ៍តាមបែបសមាហរណកម្ម
- ប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនសន្សំសំចៃនិងមិនប៉ះពាល់ដល់បរិស្ថាន
- បង្កើតប្រព័ន្ធទំនាក់ទំនងសម្រាប់មធ្យោបាយដឹកជញ្ជូនសាធារណៈ
- ប្រើប្រាស់គំនូសផ្លូវឆ្លាតវៃដែលមានចំណាំងផ្លាតនិងភ្លឺក្នុងពេលធ្វើចរាចរនៅពេលយប់
- បំពាក់អំពូលឆ្លាតវៃនៅតាមដងផ្លូវដែលជាប្រភេទអំពូលមានការសន្សំសំចៃខ្ពស់និងគ្រប់គ្រងថាមពលដោយស្វ័យប្រវត្តិ
- បំពាក់កាមេរ៉ាសុវត្ថិភាពតាមដងផ្លូវនិងទីប្រជុំជនសំខាន់ៗក្នុងខណ្ឌដើម្បីត្រួតពិនិត្យចរាចរជាទូទៅនៅតាមដងផ្លូវក៏ដូចជាទីសាធារណៈនានាដើម្បីធានាសុវត្ថិភាពជូនប្រជាជននិងបង្ក្រាបនូវរាល់សកម្មភាពអវិជ្ជមានដែលកើតមានឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព និងពន្លឿនការស្រាវជ្រាវរកមុខសញ្ញាចំពោះករណីណាមួយដែលកើតមានឡើង។

ខ.២- កសាងផ្លូវដឹកជញ្ជូនសាធារណៈនិងការផ្តល់ព័ត៌មាននៃពេលវេលាមកដល់

- បង្កើតប្រព័ន្ធព័ត៌មានពេលវេលាដឹកជញ្ជូនសាធារណៈដល់អ្នកដំណើរ
- ផ្តល់ការពិនិត្យព័ត៌មាននៃការធ្វើដំណើរមកដល់របស់រថយន្តសាធារណៈតាមទូរស័ព្ទដៃទំនើប។

ខ.៣- កសាងប្រព័ន្ធចតយានយន្តឆ្លាតវៃ

- កសាងសុវត្ថិភាពនិងបែងចែកចំណតសម្រាប់ចតយានយន្តផ្ទាល់ខ្លួន
- ផ្តល់ព័ត៌មានជាក់លាក់និងទាន់ពេលអំពីកន្លែងចតយានយន្ត។

**គ-ការប្រើប្រាស់ថាមពល**

គ.១- ការប្រើប្រាស់ថាមពលកកើតឡើងវិញ

- រៀបចំសន្សំសំចៃថាមពលដោយផ្តួចផ្តើមការប្រើប្រាស់ថាមពលកកើតឡើងវិញនៅតាមការិយាល័យនិងស្ថាប័នរដ្ឋ
- តាមស្ថានភាពខណ្ឌអាចធ្វើការផ្គត់ផ្គង់ថាមពលកកើតឡើងវិញដោយប្រើប្រាស់ពន្លឺព្រះអាទិត្យ។

គ.២- ការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យ

- លើកទឹកចិត្តនិងជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញដោយប្រើប្រាស់ពន្លឺព្រះអាទិត្យតាមរយៈការបំពាក់ឧបករណ៍បង្កើតថាមពលពន្លឺព្រះអាទិត្យនៅលើដំបូលអគារស្នាក់នៅ អគាររដ្ឋបាល និងកន្លែងចតយានយន្តជាដើម។

**ឃ-ធនធានទឹក**

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងនិងប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាពនិងសន្សំសំចៃ
- រៀបចំផែនការគ្រប់គ្រងនិងប្រើប្រាស់ទឹកដែលមានប្រភពមកពីទឹកភ្លៀងតាមរយៈការបង្កើនប្រសិទ្ធភាពអាងស្តុកទឹកភ្លៀងនិងការគ្រប់គ្រងទឹកជម្រាល។

ង-ការការពារគ្រោះមហន្តរាយ

- រៀបចំប្រព័ន្ធឆ្លាតវៃនិងផ្លូវសុវត្ថិភាពក្នុងការជម្លៀសចេញពីគ្រោះមហន្តរាយ
- រៀបចំប្រព័ន្ធតាមដាននិងផ្តល់ព័ត៌មានអំពីគ្រោះមហន្តរាយឱ្យបានទាន់ពេលវេលាដើម្បីជូនដំណឹងដល់សាធារណជននៅពេលមានគ្រោះអាសន្ននានាកើតឡើងតាមរយៈទូរស័ព្ទដៃទំនើបឬតាមបណ្តាញសង្គមនានាឱ្យបានឆាប់រហ័សក្នុងការធានាសុវត្ថិភាពជូនប្រជាជននិងថែរក្សាទ្រព្យសម្បត្តិ
- រៀបចំជម្រកបណ្តោះអាសន្ននិងនីតិវិធីជម្លៀសជនរងគ្រោះក្នុងពេលមានគ្រោះអាសន្ននិងរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការជម្លៀសខ្លួនដល់សាធារណជន សាលារៀន និងស្ថាប័ននានា។

ច-ការគ្រប់គ្រងបរិស្ថាន

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងនិងប្រព្រឹត្តកម្មទឹកកខ្វក់ឆ្លាតវៃ
- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងនិងប្រព្រឹត្តកម្មសំណល់រឹងឆ្លាតវៃ
- រៀបចំដំណើរការមជ្ឈមណ្ឌលគ្រប់គ្រងខណ្ឌតាមបែបសមាហរណកម្ម។

## ៤.២-យុទ្ធសាស្ត្រគ្រប់គ្រងនិងប្រើប្រាស់ដី

### ៤.២.១-ប្រភេទដីអាចសាងសង់បាន

ផ្អែកលើផែនទីប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ ចក្ខុវិស័យឆ្នាំ២០៣៥ ប្រភេទដីអាចសាងសង់បានមានផ្ទៃដីប្រមាណ៥ ០១០,០២ហិកតាស្មើនឹង៩៨,៧៥%នៃផ្ទៃដីសរុប និងសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សួនច្បារជ្រាបទឹក ដាំដើមឈើ ជួរតម្រង់ ឆ្លាតម្លាត កម្ពស់សំណង់ ចំណតរថយន្ត អាងបង្គន់អនាម័យ អាងប្រព្រឹត្តកម្មទឹកកខ្វក់ ពណ៌អគារ សោភ័ណភាព និងរចនាបថស្ថាបត្យកម្មខ្មែរនិង/ឬលក្ខណៈធម្មជាតិត្រឹមត្រូវស្របតាមបទប្បញ្ញត្តិជាធរមាន និងត្រូវបានបែងចែកជាតំបន់ដូចខាងក្រោម៖

១) តំបន់លំនៅឋានមានផ្ទៃដីប្រមាណ៣ ៣២៥,៧៤ហិកតាស្មើនឹង៦៦,៣៨%នៃផ្ទៃដីអាចសាងសង់បាន។ តំបន់លំនៅឋានត្រូវបានបែងចែកបន្តដូចខាងក្រោម៖

- តំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាប (ត្រឹមជាន់ទី២) ស្ថិតនៅក្នុងសង្កាត់ឃ្មួញ សង្កាត់ក្រាំងធ្នង់ សង្កាត់ភ្នំពេញថ្មី ផ្នែកខ្លះនៃសង្កាត់គោកឃ្លាង និងសង្កាត់ទឹកថ្លាមានផ្ទៃដីប្រមាណ ៤៧៥,៩១ហិកតាស្មើនឹង៩,៥០%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១,៥ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- តំបន់លំនៅឋានជាប់គ្នាដែលមានកម្ពស់ទាប (ត្រឹមជាន់ទី២) ស្ថិតនៅផ្នែកខ្លះនៃសង្កាត់ទឹកថ្លា សង្កាត់គោកឃ្លាង សង្កាត់អូរបែកក្អម សង្កាត់ក្រាំងធ្នង់ និងសង្កាត់ភ្នំពេញថ្មីមានផ្ទៃដីប្រមាណ ១២៣,១៥ហិកតាស្មើនឹង២,៤៦%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១,៥ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៧៥%
- តំបន់លំនៅឋានដែលមានកម្ពស់មធ្យមប្រភេទទី១ (ត្រឹមជាន់ទី៨) ស្ថិតនៅផ្នែកខ្លះក្នុងសង្កាត់ទឹកថ្លា សង្កាត់អូរបែកក្អម សង្កាត់គោកឃ្លាង និងសង្កាត់ភ្នំពេញថ្មីមានផ្ទៃដីប្រមាណ២៩៥,៦៦ហិកតាស្មើនឹង៥,៩០%នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%

- តំបន់លំនៅឋានដែលមានកម្ពស់មធ្យមប្រភេទទី២ (ត្រឹមជាន់ទី១១) ស្ថិតនៅផ្នែកខ្លះក្នុងសង្កាត់ភ្នំពេញថ្មី សង្កាត់គោកឃ្លាង សង្កាត់ក្រាំងធ្នង់ សង្កាត់ទឹកថ្លា និងសង្កាត់អូរបែកក្អមមានផ្ទៃដីប្រមាណ៨៨៥,៦១ហិកតាស្មើនឹង១៧,៦៨% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់ប្រភេទទី១ (ត្រឹមជាន់ទី១៨) ស្ថិតនៅផ្នែកខ្លះក្នុងសង្កាត់ឃ្មួញ សង្កាត់ភ្នំពេញថ្មី និងសង្កាត់ក្រាំងធ្នង់មានផ្ទៃដីប្រមាណ៥៥៣,៥០ហិកតាស្មើនឹង ១១,០៥% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- តំបន់លំនៅឋានដែលមានកម្ពស់ខ្ពស់ប្រភេទទី២ (ពីជាន់ទី១៩ឡើងទៅ) ស្ថិតនៅផ្នែកខ្លះនៃសង្កាត់ទឹកថ្លាមានផ្ទៃដីប្រមាណ៣៧០,៧៦ហិកតាស្មើនឹង៧,៤០% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%
- តំបន់លំនៅឋានចម្រុះស្ថិតនៅផ្នែកខ្លះក្នុងសង្កាត់ឃ្មួញនិងសង្កាត់ក្រាំងធ្នង់មានផ្ទៃដីប្រមាណ៦២១,១៥ហិកតាស្មើនឹង១២,៤០% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%។

២) តំបន់ពាណិជ្ជកម្មមានផ្ទៃដីប្រមាណ១០២,៨៩ហិកតាស្មើនឹង២,០៥% នៃផ្ទៃដីអាចសាងសង់បាន។ តំបន់ពាណិជ្ជកម្មត្រូវបានបែងចែកបន្តដូចខាងក្រោម៖

- តំបន់ពាណិជ្ជកម្មស្ថិតនៅផ្នែកខ្លះក្នុងសង្កាត់ភ្នំពេញថ្មី សង្កាត់គោកឃ្លាង និងសង្កាត់ទឹកថ្លាមានផ្ទៃដីប្រមាណ៣៧,១៩ហិកតាស្មើនឹង០,៧៤% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១០,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦៥%
- តំបន់ពាណិជ្ជកម្មចម្រុះស្ថិតនៅផ្នែកខ្លះក្នុងសង្កាត់ភ្នំពេញថ្មី សង្កាត់គោកឃ្លាង និងសង្កាត់ទឹកថ្លាមានផ្ទៃដីប្រមាណ៦៥,៧០ហិកតាស្មើនឹង១,៣១% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៨,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦៥%។

៣) តំបន់ចម្រុះស្ថិតនៅអមសងខាងនៃវិថីសំខាន់ៗក្នុងសង្កាត់ភ្នំពេញថ្មី សង្កាត់គោកឃ្លាង សង្កាត់ទឹកថ្លា សង្កាត់អូរបែកក្អម សង្កាត់ឃ្មួញ និងសង្កាត់ក្រាំងធ្នង់មានផ្ទៃដីប្រមាណ៣៨០,៧៥ហិកតាស្មើនឹង៧,៦០% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៨,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦៥%។

៤) តំបន់ដឹកជញ្ជូនមានដីចំណីផ្លូវសាធារណៈនិងចំណតរថយន្តក្រុងមានផ្ទៃដីប្រមាណ៩១៥,១៧ហិកតាស្មើនឹង១៨,២៧% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%។

៥) តំបន់ទេសចរណ៍ស្ថិតនៅសង្កាត់អូរបែកក្អមមានផ្ទៃដីប្រមាណ០,៦៤ហិកតាស្មើនឹង០,០១% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%។

៦) តំបន់រដ្ឋបាលនិងសេវាសាធារណៈស្ថិតនៅផ្នែកខ្លះក្នុងសង្កាត់ភ្នំពេញថ្មី សង្កាត់គោកឃ្លាង សង្កាត់ឃ្មួញ និងសង្កាត់ទឹកថ្លាមានផ្ទៃដីប្រមាណ៨៤,០៥ហិកតាស្មើនឹង១,៦៨% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%។

៧) តំបន់លម្ហសាធារណៈនិងផ្ទៃបៃតងមានទីតាំងការពារនិងថែរក្សាសួនបៃតងក្នុងបុរីពិភពថ្មី បុរីអង្គរភ្នំពេញ បុរីប៉េងហួត បុរីអ័រគីដេ និងបុរីវ៉ារីណាស្ថិតនៅសង្កាត់ភ្នំពេញថ្មី សង្កាត់គោកឃ្លាង សង្កាត់អូរបែកក្អម សង្កាត់ទឹកថ្លា សង្កាត់ក្រាំងធ្នង់ សួននិងទីលានវាយកូនហ្គោលហ្គ្រេនភ្នំពេញស្ថិតក្នុងសង្កាត់ឃ្មួញមានផ្ទៃដីប្រមាណ១០៧,២៧ហិកតាស្មើនឹង២,១៤% នៃផ្ទៃដីអាចសាងសង់បាន។ ជំរុញរៀបចំនិងអភិវឌ្ឍសួនសាធារណៈនិងសួនក្នុងតំបន់លំនៅឋានបន្ថែមឱ្យបានយ៉ាងតិច១០%នៃផ្ទៃដីអាចសាងសង់បាននៅឆ្នាំ២០៣៥។

៨) តំបន់វប្បធម៌និងសាសនាស្ថិតនៅទីទួលបុរាណ បរិវេណវត្តដូចជាវត្តឃ្មួញ វត្តទួលប្រាសាទបាក់មានផ្ទៃដីប្រមាណ២១,២៤ហិកតាស្មើនឹង០,៤២% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា២,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%។

៩) តំបន់គ្រប់គ្រងកម្ពស់ឧបសគ្គនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញស្ថិតនៅតាមបណ្តោយផ្លូវរត់នៃតំបន់គ្រប់គ្រងកម្ពស់ឧបសគ្គនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញក្នុងភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ភូមិដីថ្មីនិងភូមិរោងចក្រ សង្កាត់គោកឃ្លាងដែលមានកម្រិតកម្ពស់ជាម៉ែត្រដូចខាងក្រោម៖

- កម្ពស់អតិបរមា៨,០០ម៉ែត្រឬត្រឹមជាន់ទី១ មានដំបូលប្រក់ក្បឿង មានផ្ទៃដីប្រមាណ១,៩៩ហិកតាស្មើនឹង០,០៤% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា១,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៥០%
- កម្ពស់អតិបរមា២០,០០ម៉ែត្រឬត្រឹមជាន់ទី៤ មានផ្ទៃដីប្រមាណ៣៩,៩៦ហិកតាស្មើនឹង០,២០% នៃផ្ទៃដីអាចសាងសង់បាន ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៣,០ និងផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមា៦០%។

### ៤.២.២- ប្រភេទដីកម្រិតការសាងសង់

ផ្អែកលើផែនទីប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ ចក្ខុវិស័យឆ្នាំ២០៣៥ ប្រភេទដីកម្រិតការសាងសង់មានផ្ទៃដីប្រមាណ៦៣,៤៩ហិកតាស្មើនឹង១,២៥%នៃផ្ទៃដីសរុបគឺមានតែតំបន់ធនធានទឹកដូចខាងក្រោម៖

- ស្ថានីយបូមទឹកបុរី១០០ខ្នងជាគម្រោងស្តារអភិវឌ្ឍជួយរំដោះទឹកភ្លៀងចេញពីតំបន់បុរី១០០ខ្នង
- តំបន់ត្រឡោកបែកទទួលទឹកពីស្ថានីយបូមទឹកទួលគោក១ និងបញ្ជូនតាមប្រឡាយអូរអាគុជស្របផ្លូវរថភ្លើងត្រឡោកបែកក្នុងភូមិទំនប់ សង្កាត់ភ្នំពេញថ្មី
- មួយផ្នែកទៀតសុទ្ធសឹងជាបណ្តាញប្រឡាយមេពោងពាយទទួលទឹកពីប្រឡាយអូរអាគុជឆ្លងកាត់ផ្លូវ១០០៣ ទៅអាងស្តុកទឹកពោងពាយនិងទៅស្ថានីយបូមទឹកកប់ស្រូវ
- ការទទួលផ្ទៃទឹកភ្លៀងផ្នែកខាងលិចមានប្រឡាយមេទួលសំពៅចាប់ពីភូមិដំណាក់ សង្កាត់គោកឃ្លាងឆ្ពោះទៅបឹងកប់ស្រូវដូចគ្នា។

## ៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធត្រូវតែពង្រីងនិងលើកកម្ពស់ឱ្យដល់កម្រិតសម្រាប់បម្រើវិស័យវប្បធម៌ សាសនា សេដ្ឋកិច្ច សង្គម ទេសចរណ៍ ពាណិជ្ជកម្ម និងបរិស្ថានក្នុងខណ្ឌសែនសុខរួមមាន៖

### ៤.៣.១-ផ្លូវថ្នល់និងផ្លូវរថភ្លើង

- បន្តការសាងសង់ ជួសជុល ពង្រីក និងកែលម្អបណ្តាញហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ចាប់ពីមហាវិថី វិថី អនុវិថី និងផ្លូវតាមសង្កាត់នីមួយៗឱ្យមានភាពងាយស្រួលក្នុងការធ្វើចរាចរនិងដឹកជញ្ជូន
- បន្តរៀបចំផ្លូវឱ្យល្អប្រណីត អមដោយដើមផ្កាអមសងខាងផ្លូវនិងសួនពុះចែកទ្រូងផ្លូវ ចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង ផ្លូវជនពិការ គន្លងផ្លូវទោចក្រយាន បរិក្ខារផ្លូវថ្នល់ដែលមានបរិស្ថានធម្មជាតិស្រស់បំព្រងបង្គោលភ្លើង និងភ្លើងលម្អប្រកបដោយក្បូរក្បាច់រចនាបថខ្មែរនិងធម្មជាតិ និងសក្តានុពលទាក់ទាញទេសចរនិងអ្នកដំណើរឆ្លងកាត់
- រៀបចំកំណត់កម្ពស់ផ្លូវនិងចិញ្ចើមផ្លូវដោយមានកម្ពស់០,២ម៉ែត្រធៀបជាមួយនឹងកម្រិតកម្ពស់ទ្រូងផ្លូវ មានមុំជម្រាល០,១% និងមានបទដ្ឋានបច្ចេកទេសតែមួយដើម្បីមានភាពងាយស្រួលសម្រាប់អ្នកថ្មើរជើងនិងធានាបាននូវសុវត្ថិភាព
- សាងសង់ស្ពានថ្មើរជើងរំលងមហាវិថីសំខាន់ៗនិងផ្លូវថ្មើរជើងក្រោមដីដែលមានចរាចរមមាញឹកដើម្បីសម្រួលនិងបញ្ចៀសគ្រោះថ្នាក់ចរាចរ
- សិក្សាការបើកផ្លូវ ច្រកផ្លូវ និងពង្រីកទ្រូងផ្លូវបន្ថែមដើម្បីបង្កភាពងាយស្រួលដល់ចរាចរណ៍សាធារណៈ ការធ្វើអភិបាលកិច្ចល្អ និងនគរូបនីយកម្មល្អ
- បន្តកែលម្អបណ្តាញផ្លូវមេសំខាន់ៗជាផ្លូវឯកទិសដោយសាងសង់ស្ពានអាកាសនៅចំណុចប្រសព្វផ្លូវឆ្លងកាត់ស្របតាមការវិវឌ្ឍនៃចរាចរណ៍ក្នុងរាជធានីភ្នំពេញដើម្បីសម្រួលចរាចរណ៍សាធារណៈ
- រៀបចំគន្លងផ្លូវរថយន្តសាធារណៈនៅតាមផ្លូវសំខាន់ៗនិងតំបន់ទីប្រជុំជនដើម្បីសម្រួលដល់ការធ្វើចរាចរនៃរថយន្តសាធារណៈក៏ដូចជាលើកទឹកចិត្តដល់ប្រជាជនឱ្យប្រើប្រាស់សេវារថយន្តសាធារណៈ
- សិក្សារៀបចំទីតាំងចំណតរថយន្តក្រោមដីដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍
- ជំរុញអនុវត្តសេចក្តីសម្រេចលេខ០៣៩ សសរ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់ស្ថាបត្យកម្មចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយានសម្រាប់សាធារណជននិងជនពិការដើម្បីធានាសោភ័ណភាពសាធារណៈនិងការធ្វើចរាចរណ៍ប្រកបដោយសុវត្ថិភាព សុខុមាលភាពនិងភាពងាយស្រួលដល់សាធារណជននិងជនពិការ
- រក្សាការពារដីចំណីផ្លូវរថភ្លើងដើម្បីការដឹកជញ្ជូនដោយសុវត្ថិភាព
- គាំទ្រការសាងសង់ផ្លូវរថភ្លើងបន្ថែមដើម្បីសម្រួលការកកស្ទះចរាចរណ៍និងកែលម្អបណ្តាញផ្លូវរថភ្លើងដែលមានស្រាប់ឱ្យមានសណ្តាប់ធ្នាប់ដើម្បីសម្រួលចរាចរណ៍សាធារណៈ។

### ៤.៣.២-ផ្លូវទឹក

- កំណត់កម្រិតកម្ពស់សូន្យសម្រាប់ការអភិវឌ្ឍនិងការសាងសង់ក្នុងតំបន់នីមួយៗនៃខណ្ឌ

- ការពារប្រឡាយបង្ហូរទឹកពីការសាងសង់សំណង់ផ្សេងៗដែលប៉ះពាល់ដល់ទីសាធារណៈរបស់រដ្ឋ
- សិក្សាសំណង់ បណ្តាញលូ ប្រឡាយឆ្លងកាត់ផ្លូវភូមិ សង្កាត់ ខណ្ឌដើម្បីការពារការបាក់ស្រុតដីដែលធ្វើឱ្យប៉ះពាល់ចរន្តទឹក បរិស្ថាន និងការរស់នៅរបស់ប្រជាជន
- សិក្សាការចាក់ដីបំពេញឡូត៍នៅតាមតំបន់ងាយលិចលង់ដែលតម្រូវឱ្យម្ចាស់ដីស្នើសុំលិខិតអនុញ្ញាតអភិវឌ្ឍដីជាមុន។

**៤.៣.៣- ផ្លូវអាកាស**

- រក្សាលម្ហអាកាសពីការសាងសង់សំណង់ផ្សេងៗដោយកំណត់កម្ពស់សំណង់ក្នុងតំបន់គ្រប់គ្រងកម្ពស់ឧបសគ្គនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញស្របតាមព្រះរាជក្រមលេខ នស/រកម/០១០៨/០០៣ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៨ និងច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យលទ្ធភាពដល់អគារមន្ទីរពេទ្យដែលត្រូវរៀបចំឱ្យមានចំណតឧទ្ធម្ភាគចក្រ និងនិមិត្តសញ្ញាពេទ្យនៅលើដំបូលអគារដើម្បីជួយសង្គ្រោះបន្ទាន់
- បំពាក់ភ្លើងសញ្ញាពណ៌ក្រហមនៅតាមជ្រុងនៃអគារតាមបទដ្ឋានបច្ចេកទេសរបស់អាកាសចរស៊ីវិល។

**៤.៣.៤- ថាមពលអគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា**

- បន្តកែលម្អបណ្តាញអគ្គិសនីនិងទូរគមនាគមន៍ឱ្យស្របទៅតាមបទដ្ឋានបច្ចេកទេស ចៀសវាងបង្កគ្រោះថ្នាក់និងបាត់បង់នូវសោភ័ណភាពខណ្ឌ
- រៀបចំឱ្យមានប្រព័ន្ធសុវត្ថិភាពស្វ័យប្រវត្តិនៅទីសាធារណៈដើម្បីងាយស្រួលគ្រប់គ្រងអន្តរាគមន៍ឱ្យបានទាន់ពេលវេលាដើម្បីធានាបាននូវសុវត្ថិភាពក្នុងការរស់នៅ
- បន្តជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ
- បន្តជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់រថយន្តដើរដោយអាគុយ
- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទូរគមនាគមន៍និងប្រព័ន្ធព័ត៌មានវិទ្យាដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងពាណិជ្ជកម្ម។

**៤.៣.៥- ហេដ្ឋារចនាសម្ព័ន្ធសង្គមនិងវប្បធម៌**

- ជំរុញ ស្តារ និងរៀបចំលម្ហសាធារណៈ ផ្ទៃបៃតង សួនសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និងសាសនាដល់មនុស្សគ្រប់វ័យរួមមានកុមារ យុវជន ស្ត្រី បុរស មនុស្សវ័យចាស់ និងជនពិការឱ្យទទួលបាននូវសេវាប្រកបដោយសមធម៌
- រៀបចំឱ្យមានចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង គន្លងផ្លូវទោចក្រយាន បង្គន់អនាម័យ និងបរិក្ខារសម្រាប់សាធារណជននិងជនពិការដើម្បីធានាសោភ័ណភាពសាធារណៈនិងការធ្វើចរាចរណ៍ប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួលដល់សាធារណជននិងជនពិការ
- រៀបចំឱ្យមានសាលារៀននិងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈគ្រប់គ្រាន់ក្នុងខណ្ឌស្របតាមអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងបទដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- រៀបចំកែលម្អនិងពង្រីកសេវាកម្មសុខាភិបាលនៅគ្រប់កម្រិតមានជាអាទិ៍ប៉ុស្តិ៍សុខភាព កន្លែងសង្គ្រោះបន្ទាន់ មណ្ឌលសុខភាព មន្ទីរពេទ្យ ឱសថស្ថាននៅក្នុងខណ្ឌស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងសុខាភិបាល
- រៀបចំឱ្យមានសួនជ្រាបទឹកនៅតាមទីសាធារណៈ តាមបុរី និងតាមដីឡូត៍នីមួយៗ
- រៀបចំកែលម្អទីវត្តអារាម សួនច្បារ ផ្ទៃបៃតង និងថែរក្សាសម្បត្តិវប្បធម៌ ប្រពៃណី និងព្រះពុទ្ធសាសនាឱ្យមានគុណភាព សោភ័ណភាព និងអត្តសញ្ញាណជាតិល្អប្រពៃ។

### ៤.៣.៦- ការផ្គត់ផ្គង់ទឹកស្អាត

- បន្តលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតដោយយកចិត្តទុកដាក់លើគុណភាពនិងបរិមាណ
- ជំរុញការថែទាំនិងកែលម្អបណ្តាញចែកចាយទឹកស្អាត
- បង្កើតឱ្យមានទំនើបកម្មស្ថានីយប្រព្រឹត្តកម្មទឹកស្អាតក្នុងខណ្ឌសម្រាប់ស្តុកនិងចែកចាយទឹកស្អាត
- ជំរុញនិងលើកទឹកចិត្តឱ្យមានការវិនិយោគលើវិស័យទឹកស្អាតដោយប្រើប្រាស់នូវបច្ចេកទេសអាងប្រព្រឹត្តកម្មទឹកស្អាត
- សិក្សាប្រភពទឹកផ្សេងទៀតដើម្បីផ្គត់ផ្គង់ទឹកស្អាតសម្រាប់ខណ្ឌដោយចៀសវាងការប្រើប្រាស់ប្រភពទឹកក្រោមដី
- រៀបចំបទប្បញ្ញត្តិនិងចាត់វិធានការក្នុងការការពារប្រភពផ្គត់ផ្គង់ទឹកដែលបណ្តាលមកពីការអភិវឌ្ឍ។

## ៤.៤- យុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច

### ៤.៤.១- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍

- ពង្រឹងមុខងារមជ្ឈមណ្ឌលទេសចរណ៍ដោយយកចិត្តទុកដាក់លើសកម្មភាពទេសចរណ៍ ពាណិជ្ជកម្មនិងធុរកិច្ច
- បន្តការអភិវឌ្ឍទេសចរណ៍សម្រាប់ការស្នាក់នៅរយៈពេលយូរប្រកបដោយផាសុកភាពតាមរយៈការរៀបចំខណ្ឌឱ្យមានសុវត្ថិភាព បរិស្ថានរស់នៅល្អ ខ្យល់អាកាសល្អបរិសុទ្ធ ទិដ្ឋភាពធម្មជាតិជាមួយនឹងសេវាកម្មល្អ ការត្រួតពិនិត្យគុណភាពចំណីអាហារប្រកបដោយអនាម័យនិងការប្រកួតប្រជែងដោយបន្តការសាងសង់សណ្ឋាគារកម្រិតស្តង់ដា ផ្ទះសំណាក់ ភោជនីយដ្ឋាន ភេសជ្ជដ្ឋាន អគារសុខភាព និងក្លឹបកម្សាន្ត
- បន្តផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវសក្តានុពលទេសចរណ៍ក្នុងខណ្ឌតាមរយៈគេហទំព័រទេសចរណ៍និងបណ្តាញព័ត៌មានសង្គមសម្រាប់ការប្រកួតប្រជែង
- បន្តកែលម្អសួនច្បារ បណ្តាញផ្លូវ បណ្តាញលូ បណ្តាញទឹកស្អាត និងបណ្តាញអគ្គិសនី
- បន្តអភិវឌ្ឍខណ្ឌសែនសុខជាតំបន់លំនៅឋាននិងពាណិជ្ជកម្មប្រកបដោយសុខដុមនីយកម្មបែបទំនើប
- បន្តពង្រឹងសេវាកម្មទេសចរណ៍និងបដិសណ្ឋារកិច្ចឱ្យឈានដល់កម្រិតស្តង់ដាជាតិនិងអន្តរជាតិ និងបុគ្គលិកនិងអ្នកគ្រប់គ្រងសេវាកម្មទេសចរណ៍ទទួលបានជំនាញវិជ្ជាជីវៈច្បាស់លាស់
- បន្តកែលម្អនិងរៀបចំមហាវិថី វិថី អនុវិថី ប្រព័ន្ធចរាចរណ៍ ចំណតរថយន្ត សញ្ញាបង្ហាញផ្លូវទេសចរប្រព័ន្ធការពារសុវត្ថិភាព ផ្លូវសម្រាប់ដឹកជញ្ជូន ផ្លូវសម្រាប់ថ្មើរជើង និងគន្លងផ្លូវរទេះរុញក្រយានស្រប

តាមបទដ្ឋានបច្ចេកទេសអភិវឌ្ឍបៃតងដោយធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងគុណភាពបរិស្ថានល្អ

- លើកកម្ពស់ប្រសិទ្ធភាពនៃការការពារនិងអភិរក្សតំបន់អេកូទេសចរណ៍និងធនធានធម្មជាតិដោយត្រូវកំណត់ដីចំណីបឹង ផ្លូវថ្មើរជើងតាមបណ្តោយបឹង និងតំបន់ការពារទេសភាព
- ធ្វើសមាហរណកម្មតំបន់ទេសចរណ៍ក្នុងខណ្ឌជាមួយនឹងតំបន់ទេសចរណ៍ក្នុងរាជធានីភ្នំពេញ
- យកចិត្តទុកដាក់និងពង្រឹងសុវត្ថិភាពប្រព័ន្ធឬមធ្យោបាយសង្គ្រោះបន្ទាន់ជាពិសេសត្រូវបណ្តុះបណ្តាលមន្ត្រីជំនាញសង្គ្រោះបន្ទាន់ឬសង្គ្រោះបឋម សន្តិសុខការពារតាមទីប្រជុំជនសំខាន់ៗ ព្រមទាំងមានសម្ភារៈសង្គ្រោះគ្រប់គ្រាន់
- សុវត្ថិភាពចំណីអាហារត្រូវយកចិត្តទុកដាក់ដោយជំរុញលើកកម្ពស់អនាម័យ ប្រព័ន្ធត្រួតពិនិត្យស្តង់ដានិងបញ្ហាជំងឺឆ្លងតាមរយៈចំណីអាហារ
- បន្តការរៀបចំនិងអភិវឌ្ឍផលិតផលទេសចរណ៍និងការរៀបចំកែច្នៃផលិតផលឱ្យមានលក្ខណៈជាតិ
- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងសាធារណៈខណ្ឌសែនសុខលើវិស័យទេសចរណ៍
- កែច្នៃទីតាំងផ្លូវថ្មើរជើងក្រោមដីនិងលើអាកាស សួនច្បារលម្ហែកម្សាន្ត ចំណតរថយន្ត សួនកុមារទីលានសម្រាប់ប្រជាជនមកពីខេត្តឆ្ងាយៗកម្សាន្តនិងសេវាបម្រើទេសចរណ៍ផ្សេងៗទៀត។

## ៤.៤.២- យុទ្ធសាស្ត្រគាំទ្រការអភិវឌ្ឍវិស័យកសិកម្មនិងផ្សព្វផ្សាយផលិតផលក្នុងស្រុក

- រៀបចំឱ្យមានទីផ្សារលក់ផលិតផលកសិកម្មនិងផ្សព្វផ្សាយផលិតផលក្នុងស្រុក
- បង្កើនគុណភាពផលិតផលនិងផ្សព្វផ្សាយផលិតផលផ្សេងៗដែលផលិតដោយសិប្បករនៅមូលដ្ឋានឬអ្នកជំនួញក្នុងខណ្ឌ
- ជំរុញគ្រប់ផ្សារទាំងអស់នៅក្នុងខណ្ឌត្រូវមានកន្លែងលក់ផលិតផលដែលផលិតដោយសិប្បករក្នុងមូលដ្ឋាន
- ធ្វើសមាហរណកម្មសេដ្ឋកិច្ចខណ្ឌទៅក្នុងវិស័យទេសចរណ៍ដើម្បីលើកកម្ពស់ទំនិញដែលផលិតដោយសិប្បករក្នុងខណ្ឌនិងរៀបចំផ្លូវកម្សាន្តសម្រាប់តំបន់ទេសចរណ៍
- អភិវឌ្ឍផលិតផលសិប្បកម្មតាមតម្រូវការទីផ្សារទេសចរណ៍
- ពិនិត្យលទ្ធភាពក្នុងការកំណត់ទីតាំងរៀបចំនិងអភិវឌ្ឍតំបន់សិប្បកម្មតាមសង្កាត់ផ្សារភ្ជាប់ជាមួយទេសចរណ៍
- សិក្សាទីផ្សារនិងផ្សព្វផ្សាយផលិតផលសិប្បកម្មដែលមានគុណភាពល្អក្នុងខណ្ឌ
- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយនិងមណ្ឌលព័ត៌មានអំពីស្តង់ដាបច្ចេកទេសសិប្បកម្មដល់ប្រជាពលរដ្ឋ
- សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធដើម្បីលុបបំបាត់ឱ្យបាននូវការធ្វើសិប្បកម្មដែលមិនគោរពតាមបទដ្ឋានបច្ចេកទេសនិងបទដ្ឋានគតិយុត្តជាធរមាន
- អភិវឌ្ឍធនធានមនុស្សដោយជំរុញការបណ្តុះបណ្តាលជំនាញដល់សិប្បករដោយអនុវត្តតាមបទដ្ឋានសិប្បកម្មនិងចលនាផ្ទៃកងឯកជនឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋាន។

### ៤.៤.៣- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យឧស្សាហកម្មនិងសេវាកម្ម

- រៀបចំបែងចែកតំបន់ឧស្សាហកម្មឱ្យសមស្របទៅតាមបទដ្ឋានបច្ចេកទេសនិងត្រូវមានទីតាំងដាច់ចេញពីតំបន់លំនៅឋាន
- លើកទឹកចិត្តដល់អ្នកវិនិយោគជាតិនិងអន្តរជាតិដែលមកធ្វើឧស្សាហកម្មបៃតងក្នុងខណ្ឌ
- បង្កើនសួនឧស្សាហកម្មសម្រាប់សហគ្រាសខ្នាតតូចនិងមធ្យមសំដៅតភ្ជាប់រវាងសហគ្រាសខ្នាតធំក្រៅប្រទេសនិងសហគ្រាសនៅក្នុងស្រុក ជាពិសេសការចូលរួមក្នុងខ្សែសង្វាក់តម្លៃនិងខ្សែសង្វាក់ផលិតកម្មក្នុងតំបន់
- ជំរុញអភិវឌ្ឍឧស្សាហកម្មធុនស្រាលឬសិប្បកម្មដែលប្រើប្រាស់គ្រឿងម៉ាស៊ីនស្វ័យប្រវត្តិទំនើបសម្រាប់កែច្នៃផលិតផលក្នុងស្រុកនិងសម្ភារៈប្រើប្រាស់ផ្សេងៗដើម្បីបំពេញតម្រូវការរបស់ប្រជាពលរដ្ឋក្នុងខណ្ឌក៏ដូចជាក្នុងរាជធានីនិងសម្រាប់ការចែកចាយទាំងក្នុងនិងក្រៅប្រទេស
- លើកទឹកចិត្តការវិនិយោគរោងចក្រកាត់ដេរ វាយនភ័ណ្ឌ សហគ្រាស រោងចក្រដំឡើងយានយន្តនិងគ្រឿងអេឡិចត្រូនិច និងសិប្បកម្មដែលអាចបង្កើតការងារជូនប្រជាពលរដ្ឋដើម្បីលើកស្ទួយជីវភាពរស់នៅប្រចាំថ្ងៃ
- ផ្លាស់ប្តូរទីតាំងរោងចក្រ សហគ្រាស សិប្បកម្ម ស្ថានីយប្រេងឥន្ធនៈ និងអាជីវកម្មបច្ចុប្បន្នដែលប៉ះពាល់ដល់បរិស្ថាននិងសុខភាពឱ្យទៅសាងសង់និងកែសម្រួលឡើងវិញស្របតាមស្តង់ដាបរិស្ថាននិងតាមប្លង់គោលប្រើប្រាស់ដីខណ្ឌ
- លើកកម្ពស់ការប្រកួតប្រជែងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈវិស័យឧស្សាហកម្មនិងលើកទឹកចិត្តដល់អង្គភាពនិង/ឬក្រុមហ៊ុនឱ្យមានស្នាដៃល្អ។

### ៤.៤.៤- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យពាណិជ្ជកម្មនិងធុរកិច្ច

- ធ្វើការបែងចែកតំបន់សម្រាប់ការវិនិយោគពាណិជ្ជកម្មបច្ចុប្បន្ននិងទៅអនាគតឱ្យបានច្បាស់លាស់និងត្រឹមត្រូវ
- កែលម្អនិងពង្រីកទីផ្សារលក់ដូរដើម្បីឱ្យប្រជាពលរដ្ឋនិងអាជីវករក្នុងផ្សារមានកន្លែងលក់ដូរធំទូលាយសមស្របនិងមានសណ្តាប់ធ្នាប់
- កែលម្អទីផ្សារមានស្រាប់ទាំងឯកជននិងរដ្ឋឱ្យមានលក្ខណៈស្តង់ដារួមមានចំណតយានយន្ត ច្រកដើរក្នុងផ្សារ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី តំបន់បៃតង និងហេដ្ឋារចនាសម្ព័ន្ធកម្សាន្តឱ្យមានរបៀបរៀបរយនិងសណ្តាប់ធ្នាប់
- រៀបចំថ្មីឬកែលម្អទីផ្សារលក់ដូរដែលមានស្រាប់ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងជីវភាពរស់នៅរបស់ប្រជាជន
- គាំទ្រឱ្យមានការវិនិយោគផ្សារទំនើប ហាងទំនិញ ផ្សាររាត្រី មជ្ឈមណ្ឌលពាណិជ្ជកម្ម ធនាគារ ឃ្លាំងនិងសហគ្រាសផ្សេងៗដើម្បីងាយស្រួលក្នុងការដោះដូរទំនិញ បង្កើតការងារ និងលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ចឱ្យបានខ្លាំងក្លា
- រៀបចំដេប៉ូស្តុកទំនិញសម្រាប់ចែកចាយក្នុងខណ្ឌនិងតំបន់ជុំវិញនិងសាងសង់ហេដ្ឋារចនាសម្ព័ន្ធឱ្យបានល្អដើម្បីជួយសម្រួលដល់ការដឹកជញ្ជូន

- បង្កើតការរៀបចំការតាំងពិព័រណ៍និងផ្សព្វផ្សាយផលិតផលគ្រប់ប្រភេទដើម្បីបង្កើនការផលិតនិងជំរុញសេដ្ឋកិច្ចឱ្យបានខ្លាំងក្លា។

## ៤.៥-យុទ្ធសាស្ត្រអភិវឌ្ឍសង្គមកិច្ចនិងវប្បធម៌

- ដោះស្រាយសំណង់មិនរៀបរយនៅលើដីសាធារណៈនិងដីឯកជនរបស់រដ្ឋជាពិសេសនៅតាមផ្លូវច្រកផ្លូវ ដីចំណីប្រឡាយអូរអាគុជនិងប្រឡាយទួលសំពៅ ដីចំណីផ្លូវរថភ្លើង និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត
- សិក្សាលទ្ធភាពនិងរៀបចំគម្រោងកែលម្អតំបន់លំនៅឋានរបស់សហគមន៍ក្រីក្រនិងប្រជាជនរស់នៅក្នុងសំណង់មិនរៀបរយតាមរយៈការអភិវឌ្ឍនៅនឹងកន្លែងឬបំលាស់ទីតាំងថ្មី
- ជំរុញលើកទឹកចិត្តដល់អ្នកវិនិយោគក្នុងការសាងសង់លំនៅឋានមានតម្លៃសមរម្យសម្រាប់ប្រជាជនដែលមានប្រាក់ចំណូលទាប
- លើកទឹកចិត្តឱ្យមានការចូលរួមពីអង្គការ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលលើការងារមនុស្សធម៌សម្រាប់ប្រជាជនក្រីក្រ
- ពង្រឹងសេវាកម្មដោះស្រាយហានិភ័យសង្គ្រោះបន្ទាន់ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងគ្រោះមហន្តរាយ
- ពង្រឹងការបម្រើសេវាកម្មសាធារណៈឱ្យមានអភិបាលកិច្ចល្អ គ្រប់ជំនាញទាំងអស់ និងលើកទឹកចិត្តការប្រតិបត្តិតាមច្រកចេញចូលតែមួយ
- ជំរុញនិងកែលម្អគ្រប់ស្ថានីយប្រេងឥន្ធនៈឱ្យមានបង្គន់អនាម័យសាធារណៈសម្រាប់បុរស ស្ត្រី និងជនពិការ។

## ៤.៦-យុទ្ធសាស្ត្រការពារបរិស្ថាន ធនធានធម្មជាតិ និងគ្រប់គ្រងសំណល់

### ៤.៦.១- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង

- ពង្រឹងយន្តការនិងហេដ្ឋារចនាសម្ព័ន្ធក្នុងការគ្រប់គ្រងសំណល់រឹង
- គ្រប់គ្រងមិនឱ្យមានសំណល់រឹងតាមទីសាធារណៈ
- លើកកម្ពស់ទំនើបកម្មមធ្យោបាយនិងបរិក្ខារប្រមូលសំណល់រឹងនិងរៀបចំទីតាំងសម្រាប់ទុកដាក់សំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេសនិងស្តង់ដាទីក្រុងស្អាត
- អភិវឌ្ឍបច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងសំណល់រឹង
- ជំរុញឱ្យមានការអនុវត្តគោលការណ៍កាត់បន្ថយការប្រើប្រាស់ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃប្រើប្រាស់ឡើងវិញ
- ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋនិងការវិនិយោគរបស់វិស័យឯកជននិងសាធារណៈក្នុងការគ្រប់គ្រងសំណល់រឹង
- ជំរុញអនុវត្តច្បាប់ឱ្យបានតឹងរឹងស្របតាមគោលការណ៍កាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិច ផលិតផលប៉ះពាល់បរិស្ថាននិងការកែច្នៃលើការគ្រប់គ្រងសំណល់រឹង
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាននិងអនាម័យដើម្បីធានាបាននិរន្តរភាពជាតំបន់លំនៅឋានប្រកបដោយសុខុមាលភាព។

### ៤.៦.២- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ

- រៀបចំកែលម្អនិងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀងនិងលូទឹកកខ្វក់ឱ្យដាច់ពីគ្នាដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រនិងត្រូវចម្រោះឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យមុននឹងបង្ហូរចូលប្រព័ន្ធលូសាធារណៈ
- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម និងសំណង់សាធារណៈត្រូវមានអាងប្រព្រឹត្តកម្មទឹកកខ្វក់និងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- មន្ត្រីមានសមត្ថកិច្ចជំនាញសហការជាមួយអាជ្ញាធរមូលដ្ឋានត្រូវត្រួតពិនិត្យជាប្រចាំរាល់ការដ្ឋានសំណង់ក្នុងការធ្វើអាងប្រព្រឹត្តកម្មទឹកកខ្វក់និងអាងបង្គន់អនាម័យ
- រៀបចំអណ្តូងលូឱ្យមានប្រព័ន្ធចម្រោះជាមុននូវសំណល់ភក់មុននឹងបង្ហូរចូលលូសាធារណៈស្របតាមបទដ្ឋានបច្ចេកទេស
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាននិងអនាម័យដើម្បីធានាបាននិរន្តរភាពជាតំបន់លំនៅឋានប្រកបដោយសុខុមាលភាព។

### ៤.៦.៣- ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន

កំណត់និងបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ទុកដាក់សំណល់រឹងតាមគ្រប់ទីតាំងផ្សារ ទីតាំងបុរី តាមភូមិ តាមខ្នងផ្ទះ និងតាមគ្រឹះស្ថានសាធារណៈនិងឯកជនដោយមានការទុកដាក់បានត្រឹមត្រូវតាមបទដ្ឋានកំណត់និងតាមតំបន់ផ្សេងៗរួមមាន៖

- តំបន់តាមដងផ្លូវសាធារណៈ
- តំបន់តាមមាត់ប្រឡាយ
- តំបន់សហគមន៍
- តំបន់សួនច្បារសាធារណៈ។

### ៤.៦.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ

- ការពារនិងថែរក្សាតំបន់មាត់ប្រឡាយនិងដើមឈើតាមទីសាធារណៈ
- ការពារនិងថែរក្សាបណ្តាញទឹកស្អាតនិងបណ្តាញលូស្របតាមបទប្បញ្ញត្តិជាធរមាន
- កាត់បន្ថយការបំពុលខ្យល់ដោយសារម៉ាស៊ីនភ្លើងតាមរយៈការផ្គត់ផ្គង់អគ្គិសនីរដ្ឋឱ្យបានច្រើន
- លើកកម្ពស់ការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលមិនបំពុលបរិស្ថាន
- បង្កើតគណៈកម្មាធិការត្រួតពិនិត្យបរិស្ថានមានប្រសិទ្ធភាពមួយនៅថ្នាក់ខណ្ឌនិងលើកកម្ពស់ចំណេះដឹងរបស់ប្រជាជនអំពីបរិស្ថាន
- រៀបចំឱ្យមានមូលនិធិសម្រាប់ថែទាំបរិស្ថាននិងជំរុញការវិនិយោគវិស័យឯកជននិងរដ្ឋ
- ទប់ស្កាត់ការលុបបឹងនិងប្រព័ន្ធផ្លូវទឹកធម្មជាតិក្នុងការយកដីទៅសាងសង់សំណង់ផ្សេងៗ
- ទប់ស្កាត់ការបង្ហូរទឹកកខ្វក់ដែលមានការបំពុលបរិស្ថានឱ្យខានតែបានដែលបណ្តាលមកពីរោងចក្រសហគ្រាស សិប្បកម្ម និងអាជីវកម្ម។

## ៤.៧-យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ

- ជំរុញការដាំដើមឈើតាមដងផ្លូវនិងមាត់ប្រឡាយ
- ពង្រឹងសុវត្ថិភាពផ្លូវក្រវាត់រាជធានីក្នុងខណ្ឌ
- រៀបចំនិងស្តារប្រព័ន្ធប្រឡាយនិងលូបង្ហូរទឹកឱ្យស្របតាមបទដ្ឋានបច្ចេកទេស
- រៀបចំឱ្យមានឧបករណ៍ ប្រព័ន្ធការពារ និងប្រឆាំងអគ្គីភ័យ ព្រមទាំងរៀបចំក្បាលបូមពន្លត់អគ្គីភ័យនៅតាមដងផ្លូវសាធារណៈនិងតាមសំណង់អគារនានា
- បំពាក់ឧបករណ៍ការពារការវាយប្រហារដោយរន្ទះនៅតាមសំណង់អគារខ្ពស់ៗ
- បញ្ឈប់ការផ្តល់លិខិតអនុញ្ញាតសាងសង់ស្ថានីយប្រេងឥន្ទនៈនៅក្នុងខណ្ឌសែនសុខ តាមផ្លូវឧកញ៉ាម៉ុងឫទ្ធី ផ្លូវលេខ១៩៨៦ និងផ្លូវលេខ១៩២៨ ដោយផ្អែកលើគោលការណ៍អភិវឌ្ឍន៍ដោយសណ្តាប់ធ្នាប់និងសុខដុមនីយកម្ម
- ហាមសាងសង់ស្ថានីយប្រេងឥន្ទនៈនៅទីប្រជុំជនដូចជាសំណង់ដែលមានឧបនិស្ស័យខាងអប់រំវប្បធម៌ សុខាភិបាល សាសនា និងបណ្តុំលំនៅឋាន
- ការសាងសង់សំណង់គ្រប់ប្រភេទត្រូវមានចម្ងាយយ៉ាងតិច៣,៥ម៉ែត្រពីប្រព័ន្ធបញ្ជូនអគ្គិសនីដែលមានតង់ស្យុងខ្ពស់គិតពីខ្សែបញ្ជូនថាមពលដល់ចុងនៃផ្នែកដែលលយចេញនៃអគារ។

## ៤.៨-យុទ្ធសាស្ត្រពង្រឹងអភិបាលកិច្ចល្អ គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុនៅមូលដ្ឋាន

ការគ្រប់គ្រងហិរញ្ញវត្ថុនៅមូលដ្ឋានគឺជាកត្តាសំខាន់ចាំបាច់និងជាស្នូលនៃវិស័យសេដ្ឋកិច្ច ទេសចរណ៍ បរិស្ថាន និងអភិវឌ្ឍខណ្ឌដោយចាំបាច់ត្រូវៈ

- សម្របសម្រួលស្ថាប័នពាក់ព័ន្ធឱ្យចែករំលែកព័ត៌មានអំពីគម្រោងដែលត្រូវអនុវត្តនិងគម្រោងដែលត្រូវស្នើឡើងក្នុងខណ្ឌ
- ពង្រឹងមូលដ្ឋានធនធានមនុស្សទាំងនៅថ្នាក់សង្កាត់និងថ្នាក់ខណ្ឌជាពិសេសសម្រាប់ការគ្រប់គ្រងការអភិវឌ្ឍនិងការត្រួតពិនិត្យគម្រោងសាធារណៈ ការគ្រប់គ្រងដីធ្លី ការប្រមូលពន្ធ។ល។
- ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រើប្រាស់ដីសាធារណៈ ការផ្តល់លិខិតអនុញ្ញាតសាងសង់ ការផ្តល់លិខិតអនុញ្ញាតអភិវឌ្ឍដី ការចុះបញ្ជីដីធ្លី ការចុះបញ្ជីយានយន្ត ការបូមទឹកក្រោមដីរបស់ឯកជន និងការគ្រប់គ្រងបរិស្ថាន
- ពង្រឹងហិរញ្ញវត្ថុនៅមូលដ្ឋានតាមរយៈការប្រមូលចំណូលក្នុងមូលដ្ឋាន ការបែងចែកចំណូលរដ្ឋ និងប្រភពផ្សេងៗទៀតដល់រដ្ឋបាលមូលដ្ឋានសម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈជាពិសេសសម្រាប់ការជួសជុលថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងការលើកកម្ពស់សោភ័ណភាពនិងបរិស្ថានក្នុងខណ្ឌ។

## ៥-ផែនការសកម្មភាព

ផ្អែកតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ រដ្ឋបាលខណ្ឌសែនសុខនិងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តផែនការសកម្មភាពសំខាន់ៗចាំបាច់ដូចតទៅៈ

**៥.១-ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម**

តាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌសែនសុខ បទប្បញ្ញត្តិនគរូបនីយកម្មដែលត្រូវរៀបចំរួមមានៈ

- ឧបសម្ព័ន្ធទី៣ ប្លង់កំណត់កម្ពស់សំណង់តាមវិថីសំខាន់ៗ
- ឧបសម្ព័ន្ធទី៤ ប្លង់កំណត់កម្ពស់សំណង់តាមសន្ទស្សន៍ប្រើប្រាស់ដី
- ឧបសម្ព័ន្ធទី៧ គំរូចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយានសម្រាប់សាធារណជននិងជនពិការ
- ឧបសម្ព័ន្ធទី១៣ ប្លង់អាងបង្គន់អនាម័យនិងអាងប្រព្រឹត្តកម្មទឹកកខ្វក់
- ឧបសម្ព័ន្ធទី១៤ ការកំណត់លេខផ្លូវនិងលេខផ្ទះ
- ឧបសម្ព័ន្ធទី១៥ តំបន់ប្រើប្រាស់ដី កម្ពស់សំណង់ និងប្រភេទសំណង់។

**៥.២-ការផ្សព្វផ្សាយ**

រៀបចំប្រជុំផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខដល់ក្រុមអ្នកជំនាញ រដ្ឋបាលខណ្ឌ វិនិយោគិន ប្រជាពលរដ្ឋ និងផ្សព្វផ្សាយតាមរយៈគេហទំព័រឬតាមបណ្ដាញសង្គមនៃប្រព័ន្ធអេឡិចត្រូនិចរបស់រដ្ឋបាលខណ្ឌសែនសុខ។

**៥.៣-ការអនុវត្តគម្រោងតាមវិស័យ**

គម្រោងសំខាន់ៗដែលត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍខណ្ឌ ទេសចរណ៍ ការដឹកជញ្ជូន សិប្បកម្ម កសិកម្ម និងការផ្សព្វផ្សាយផលិតផលក្នុងស្រុក ការគ្រប់គ្រងបរិស្ថាន ធនធានទឹកនិងការផ្គត់ផ្គង់ទឹកស្អាត ការគ្រប់គ្រងសំណល់រឹង ប្រព័ន្ធលូបង្ហូរទឹកភ្លៀង ការគ្រប់គ្រងសំណល់រាវ ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍ មានដូចខាងក្រោមៈ

**៥.៣.១-ការអភិវឌ្ឍខណ្ឌ**

- កែលម្អសោភ័ណភាពនិងហេដ្ឋារចនាសម្ព័ន្ធ
- កសាងសមត្ថភាពធ្វើផែនការ
- រៀបចំបញ្ជីសារពើភ័ណ្ឌស្ថាបត្យកម្មប្រវត្តិសាស្ត្រដែលមានតម្លៃសម្រាប់ការអភិរក្ស
- អភិវឌ្ឍតំបន់លំនៅឋាន
- ធ្វើផែនការអភិវឌ្ឍន៍តំបន់វប្បធម៌ ពាណិជ្ជកម្ម ទេសចរណ៍ និងសណ្ឋាគារ។

**៥.៣.២-ការអភិវឌ្ឍទេសចរណ៍**

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងបណ្ដាញទេសចរណ៍
- អភិវឌ្ឍផ្សាររាត្រី
- លើកកម្ពស់ទេសចរណ៍គុណភាពតាមរយៈភាពជាដៃគូរវាងរដ្ឋនិងឯកជន
- លើកកម្ពស់សហគមន៍ទេសចរណ៍
- អភិវឌ្ឍនិងលើកកម្ពស់ទេសចរណ៍តាមភូមិនិងទេសចរណ៍ធម្មជាតិ
- បណ្ដុះបណ្ដាលមគ្គុទេសក៍ទេសចរណ៍និងការផ្ដល់លិខិតអនុញ្ញាត
- សិក្សាលម្អិតអំពីលទ្ធភាពទទួលភ្ញៀវទេសចរនិងការគ្រប់គ្រងរមណីយដ្ឋាន។

### ៥.៣.៣- ការអភិវឌ្ឍការដឹកជញ្ជូន

- កសាងស្ពានអាកាសថ្មីបន្ថែមនិងស្ពានអាកាសថ្មើរជើងសម្រាប់ឆ្លងកាត់ផ្លូវនៅទីតាំងដែលមានចរាចរណ៍មមារញឹក
- កែលម្អបណ្តាញផ្លូវមេសំខាន់ៗជាផ្លូវឯកទិសនិងសាងសង់ស្ពានអាកាសថ្មើរជើង
- រៀបចំចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយានសម្រាប់សាធារណជននិងជនពិការ
- សាងសង់និងកែលម្អផ្លូវក្រវាត់រាជធានីក្នុងខណ្ឌ
- កែលម្អនិងសាងសង់បណ្តាញផ្លូវ
- លើកកម្ពស់សណ្តាប់ធ្នាប់និងយុទ្ធនាការសម្រាប់ការពារសុវត្ថិភាពតាមផ្លូវថ្នល់
- រៀបចំមធ្យោបាយដឹកជញ្ជូនសាធារណៈដែលមិនបំពុលបរិស្ថាន
- ពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ថែទាំផ្លូវឱ្យមានប្រសិទ្ធភាព។

### ៥.៣.៤- ការពង្រឹងកសិកម្ម សិប្បកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក

- អភិវឌ្ឍធនធានមនុស្សនិងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលសិប្បកម្ម
- ចលនាសហគមន៍ភូមិមួយផលិតផលមួយ
- អភិវឌ្ឍសហគមន៍ផលិតកម្ម
- តាំងពិព័រណ៍ផលិតផលសិប្បកម្ម
- ពង្រឹងទីផ្សារសម្រាប់តាំងនិងលក់ផលិតផលសិប្បកម្ម។

### ៥.៣.៥- ការគ្រប់គ្រងពាណិជ្ជកម្ម

- រៀបចំសណ្តាប់ធ្នាប់ឱ្យល្អប្រសើរក្នុងតំបន់ពាណិជ្ជកម្ម
- រៀបចំភ្លើងអគ្គិសនីសម្រាប់ប្រើប្រាស់ក្នុងតំបន់ពាណិជ្ជកម្មជាការបំភ្លឺនិងផ្តល់ថាមពលគ្រប់គ្រាន់ក្នុងការលើកដាក់ទំនិញ
- រៀបចំឱ្យមានកន្លែងដោះដូរទំនិញក្នុងបរិវេណទីផ្សារឱ្យមានទីតាំងចំណតនិងចំណតបណ្តោះអាសន្នឱ្យស្របទៅតាមបទដ្ឋានបច្ចេកទេស
- រៀបចំឱ្យមានទីតាំងចំណតរថយន្តឱ្យស្របទៅតាមបទដ្ឋានបច្ចេកទេស។

### ៥.៣.៦- ការគ្រប់គ្រងបរិស្ថាន

- ពង្រឹងសមត្ថភាពស្ថាប័ន
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
- ប្រែក្លាយខណ្ឌសែនសុខឱ្យក្លាយជាកន្លែងរស់នៅដែលមានលក្ខណៈល្អប្រសើរ
- បង្កើនទីតាំងលម្ហនិងតំបន់បៃតងក្នុងខណ្ឌក៏ដូចជាក្នុងលំនៅឋាននិងអគារឯកជននិងរដ្ឋ។

### ៥.៣.៧- ការផ្គត់ផ្គង់ទឹកស្អាតនិងធនធានទឹក

- ត្រួតពិនិត្យបណ្តាញផ្គត់ផ្គង់ទឹកស្អាត
- បំពាក់បំពង់បង្ហូរទឹកថ្មីជំនួសបំពង់ទឹកចាស់ៗ។

- សិក្សាអំពីយុទ្ធសាស្ត្រសមាហរណកម្មនៃការគ្រប់គ្រងធនធានទឹក
- អភិវឌ្ឍបណ្តាញផ្គត់ផ្គង់ទឹកថ្មីរហូតដល់ឆ្នាំ២០៣៥
- អភិវឌ្ឍរោងចក្រប្រព្រឹត្តកម្មទឹកស្អាតនិងបណ្តាញផ្គត់ផ្គង់ទឹកស្អាតរហូតដល់ឆ្នាំ២០៣៥។

### ៥. ៣. ៨- ការផ្គត់ផ្គង់ថាមពលអគ្គិសនីនិងទូរគមនាគមន៍

- រៀបចំប្រព័ន្ធផ្គត់ផ្គង់ថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យតាមផ្លូវនិងទីសាធារណៈ
- លើកកម្ពស់ការប្រើប្រាស់ថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ
- អភិវឌ្ឍបណ្តាញផ្គត់ផ្គង់អគ្គិសនីនិងទូរគមនាគមន៍ឱ្យមានសណ្តាប់ធ្នាប់និងសោភ័ណភាព
- ដំឡើងនិងជួសជុលបណ្តាញអគ្គិសនីបំភ្លឺតាមផ្លូវនិងទីសាធារណៈ
- ធ្វើផែនការប្រើប្រាស់ថាមពលអគ្គិសនីប្រកបដោយប្រសិទ្ធភាពខ្ពស់
- ពិនិត្យឡើងវិញនូវអត្រាតម្លៃអគ្គិសនី។

### ៥. ៣. ៩- ការគ្រប់គ្រងសំណល់រឹង

- រៀបចំប្រព័ន្ធគ្រប់គ្រងសំណល់រឹង
- ពង្រឹងប្រព័ន្ធប្រមូលសំណល់រឹង
- រៀបចំកន្លែងទុកដាក់សំរាមបណ្តោះអាសន្នដែលមានអនាម័យ ។

### ៥. ៣.១០- ការគ្រប់គ្រងសំណល់រាវនិងប្រព័ន្ធលូបង្ហូរទឹកភ្លៀង

- អភិវឌ្ឍប្រព័ន្ធបង្ហូរទឹកភ្លៀងនិងទឹកកខ្វក់ដោយចែកឱ្យដាច់ពីគ្នាមុនបង្ហូរចូលលូសាធារណៈ
- រៀបចំនិងស្តារឡើងវិញនូវប្រព័ន្ធអាងស្តុកទឹកបណ្តោះអាសន្នតាមគេហដ្ឋាននិងទីសាធារណៈ
- គ្រប់គ្រងនិងត្រួតពិនិត្យជាប្រចាំនូវសំណល់រាវនិងអាងប្រព្រឹត្តកម្មទឹកកខ្វក់
- កែលម្អនិងពង្រីកបន្ថែមស្ថានីយនិងអនុស្ថានីយបូមទឹកកខ្វក់។

## ៥.៤-ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង

ផែនការសកម្មភាពសម្រាប់ការអនុវត្តរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែងមានដូចខាងក្រោម៖

### ៥. ៤.១- ការអនុវត្តរយៈពេលខ្លី

- កែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្តក្នុងគម្រោងអាទិភាពនៃការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិប្រើប្រាស់ដី។

### ៥. ៤. ២- ការអនុវត្តរយៈពេលមធ្យម

- គម្រោងសំខាន់ៗតាមវិស័យក្រៅពីគម្រោងអាទិភាព។

### ៥. ៤. ៣- ការអនុវត្តរយៈពេលវែង

- ចំពោះសំណង់បណ្តោះអាសន្នតាមប្រឡាយនិងការតាំងទីលំនៅត្រូវបន្តដោះស្រាយតាមសារាចរលេខ ០៣ សរ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានី ទីក្រុង និងទីប្រជុំជន

- សិក្សាពីលទ្ធភាពនៃការផ្តើប្រទានកម្មដីជូនប្រជាពលរដ្ឋក្រីក្រគ្មានលំនៅឋាននិងប្រជាពលរដ្ឋរស់នៅក្នុងសំណង់បណ្តោះអាសន្ន
- ចំពោះគម្រោងចាំបាច់ត្រូវធ្វើបច្ចុប្បន្នភាពហេដ្ឋារចនាសម្ព័ន្ធសមស្របជាមុនដូចជាបណ្តាញផ្លូវនិងប្រព័ន្ធលូបង្ហូរទឹកកខ្វក់និងទឹកភ្លៀង និងប្លង់បែងចែកតំបន់ប្រើប្រាស់ដីផ្សេងៗស្របតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែងដោយអនុលោមតាមបទប្បញ្ញត្តិនគរូបនីយកម្មនិងគោលការណ៍អភិវឌ្ឍន៍បៃតង សំដៅធ្វើឱ្យខណ្ឌក្លាយជាតំបន់រស់នៅប្រកបដោយសុខុមាលភាព គុណភាព វឌ្ឍនភាព និងចីរភាព។

### ៥.៥-គម្រោងអាទិភាព

- កែលម្អសោភ័ណភាពនិងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- កសាងសមត្ថភាពធ្វើផែនការ
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
- លើកកម្ពស់គុណភាពទេសចរណ៍តាមរយៈភាពជាដៃគូរវាងរដ្ឋនិងឯកជន
- អភិវឌ្ឍធនធានមនុស្សនិងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលសិប្បកម្ម
- ស្តារនិងជួសជុលបណ្តាញផ្លូវ
- បំពាក់បំពង់បង្ហូរទឹកថ្មីជំនួសបំពង់ទឹកចាស់ៗ
- សិក្សាយុទ្ធសាស្ត្រសមាហរណកម្មនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ
- អភិវឌ្ឍប្រព័ន្ធបង្ហូរទឹកនិងសំណល់រឹងនិងរាវ។

## ៦-ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខមានជាអាទិ៍៖

- ថវិកាជាតិ
- ថវិកាអភិវឌ្ឍន៍និងវិនិយោគដោយវិស័យឯកជន
- ថវិកាវិនិយោគរវាងរដ្ឋនិងឯកជន
- ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ថវិកាពីការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

## ៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

### ៧.១-យន្តការ

យន្តការថ្នាក់ជាតិដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ ចក្ខុវិស័យឆ្នាំ២០៣៥ មាន៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួង ស្ថាប័នតាមវិស័យរបស់រដ្ឋ។

យន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ ចក្ខុវិស័យឆ្នាំ២០៣៥ មាន៖ រដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌសែនសុខ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខណ្ឌសែនសុខ មន្ទីរ អង្គភាពពាក់ព័ន្ធ និងអាជ្ញាធរសង្កាត់និងភូមិ។

## ៧.២-ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ ចក្ខុវិស័យឆ្នាំ២០៣៥ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើច្បាប់ គោលនយោបាយ និងក្របខណ្ឌគតិយុត្តមានជាអាទិ៍ច្បាប់ភូមិបាល ច្បាប់ស្តីពីសំណង់ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន គោលនយោបាយជាតិស្តីពីដីធ្លី គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីលំនៅឋាន អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ៧.៣-ភារកិច្ច នីតិវិធី និងគោលការណ៍

រដ្ឋបាលខណ្ឌសែនសុខដោយមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌសែនសុខជាសេនាធិការមានភារកិច្ចៈ

- ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពលម្អិតសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខដោយមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។ ផែនការសកម្មភាពលម្អិតខាងលើត្រូវកំណត់នូវគោលបំណង គោលដៅ សកម្មភាព ពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនាករសំខាន់ៗសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃ ព្រមទាំងត្រូវមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ប្លង់គោលប្រើប្រាស់ដីថ្នាក់ខណ្ឌ ផែនការប្រើប្រាស់ដីថ្នាក់សង្កាត់ និងប្លង់លម្អិតនគរូបនីយកម្មថ្នាក់សង្កាត់
- គោលការណ៍នៃការត្រួតពិនិត្យនិងការវាយតម្លៃត្រូវផ្អែកលើសូចនាករនៃការរៀបចំដែនដីនិងនគរូបនីយកម្មនិងសូចនាករតាមវិស័យដែលជាកត្តាគូសបញ្ជាក់អំពីប្រសិទ្ធភាពនៃប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព
- ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខក្នុងរយៈពេល៥ឆ្នាំម្តងស្របតាមគោលការណ៍និងនីតិវិធីដែលបានកំណត់ តាមពេលវេលា និងតម្រូវការចាំបាច់ជាក់ស្តែងសំដៅបម្រើផលប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ
- ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំនៃការអនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ រដ្ឋបាលរាជធានីភ្នំពេញ ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិដើម្បីធ្វើការបូកសរុបនិងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

## ៨-សេចក្តីសន្និដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទទួលបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យតាមរយៈការអនុវត្តគោលនយោបាយឈ្នះ-ឈ្នះនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខបានកំណត់នូវគោលដៅអំពីនគរូបនីយកម្មនិងធ្វើសមាហរណកម្មជាមួយបណ្តាខណ្ឌជុំវិញដោយឆ្លុះបញ្ចាំងនូវកត្តាសំខាន់ៗចំនួន៥ គឺៈ ទី១)មុខងារសមស្របសម្រាប់ការស្នាក់នៅ ការផ្តល់ការងារ ការសិក្សា ការផ្តល់សេវាកម្ម ការធ្វើចរាចរណ៍ និងកន្លែងលម្ហែកម្សាន្តប្រកបដោយសុខភាព សោភ័ណភាព សុវត្ថិភាព សណ្តាប់ធ្នាប់ និងភាពងាយស្រួល ទី២)លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការការពារបរិស្ថាន សន្តិសុខស្បៀង និងការថែរក្សាសម្បត្តិវប្បធម៌ ទី៣)លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការកែលម្អ ការអភិវឌ្ឍ និងការការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ទី៤)តុល្យភាពនៃការអភិវឌ្ឍនិងការអភិរក្ស ព្រមទាំងទំនាក់ទំនងរវាងតំបន់គម្រោងជាមួយតំបន់ជុំវិញដោយផ្អែកលើកត្តាភូមិសាស្ត្រនិងលក្ខណៈពិសេសនៃតំបន់នីមួយៗ និងទី៥)តម្រង់ទិសច្បាស់លាស់ក្នុងអំឡុងពេលអភិវឌ្ឍប្រកបដោយគុណភាព ប្រសិទ្ធភាព ចីរភាព និងសមធម៌នគរូបនីយកម្ម។ បន្ថែមលើនេះប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខជាមូលដ្ឋានសម្រាប់បន្តសិក្សាផែនការប្រើប្រាស់ដីនិងប្លង់លម្អិតនគរូបនីយកម្មថ្នាក់សង្កាត់ដើម្បីរួមចំណែកអភិវឌ្ឍនិងប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ថ្ងៃ ៧ង ១២កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**អនុសាសន៍**

ដើម្បីឱ្យប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ ចក្ខុវិស័យឆ្នាំ២០៣៥ អនុវត្តដោយជោគជ័យនិងមានប្រសិទ្ធភាព រដ្ឋបាលរាជធានីភ្នំពេញនិងក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធសូមយកចិត្តទុកដាក់៖

១) កំណត់ឱ្យបានច្បាស់លាស់នូវបញ្ហានិងបរិស្ថាននៃខណ្ឌ ក្នុងន័យទប់ស្កាត់លំហូរភ្ញៀវទេសចរចេញពីខណ្ឌនៅពេលមានការប្រកួតប្រជែងខ្ពស់ពីតំបន់ទេសចរណ៍ផ្សេងៗទៀត។

២) គ្រប់គ្រងធនធានទឹកសម្រាប់ភ្ញៀវទេសចរនិងប្រជាជនមូលដ្ឋាន និងលម្ហសាធារណៈនិងផ្ទៃបៃតងសម្រាប់សាធារណជននិងទេសចរ។

៣) សម្របសម្រួលការធ្វើផែនការប្រើប្រាស់ដីខណ្ឌសែនសុខដោយមានការចូលរួមពីប្រជាពលរដ្ឋមូលដ្ឋាន ដើម្បីធ្វើការគ្រប់គ្រងដីធ្លីប្រកបដោយប្រសិទ្ធភាព។

៤) ពិនិត្យវាយតម្លៃនិងកែលម្អប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខរៀងរាល់៥(ប្រាំ)ឆ្នាំម្តងដើម្បីឆ្លើយតបទៅនឹងកាលៈទេសៈប្រែប្រួលនិងតម្រូវការសេដ្ឋកិច្ច សង្គមជាក់ស្តែង។

៥) កសាងសមត្ថភាពមន្ត្រីជំនាញនៅថ្នាក់រាជធានី ខណ្ឌ និងលើកកម្ពស់ការចែករំលែកព័ត៌មានអំពីគម្រោងអភិវឌ្ឍនានារវាងមន្ទីរ អង្គភាព និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនៅក្នុងរាជធានីតាមរយៈគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មរាជធានីភ្នំពេញ។

៦) លើកកម្ពស់សមត្ថភាពបច្ចេកទេសសម្រាប់ការត្រួតពិនិត្យនិងថែរក្សាបរិស្ថានប្រកបដោយប្រសិទ្ធភាពដោយសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធក្នុងរាជធានី។ រដ្ឋបាលរាជធានីភ្នំពេញត្រូវរៀបចំកញ្ចប់ថវិកាដល់អាជ្ញាធរខណ្ឌសែនសុខសម្រាប់អនុវត្តផែនការជួសជុលនិងថែទាំបរិក្ខារសាធារណៈដូចជាផ្លូវ សួនច្បារ ការប្រមូលសំណល់រឹងនិងរាវ ប្រព័ន្ធបង្ហូរទឹកភ្លៀងក្នុងខណ្ឌ។ល។

៧) ត្រូវយកផែនការរូបវន្តជាមូលដ្ឋានបង្អែកសម្រាប់ការអភិវឌ្ឍដី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការសាងសង់គ្រប់ប្រភេទ និងការអភិរក្សក្នុងខណ្ឌ ព្រមទាំងការធ្វើសមាហរណកម្មជុំវិញដើម្បីធ្វើឱ្យការប្រើប្រាស់ដីបានត្រឹមត្រូវ ចំទិសដៅ ប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមធម៌។

៨) លើកកម្ពស់ប្រសិទ្ធភាពការផ្តល់សេវាសាធារណៈស្របតាមអភិក្រមរបស់រាជរដ្ឋាភិបាលគឺធ្វើឱ្យបាន ធ្វើឱ្យលឿន ធ្វើឱ្យមានគុណភាព និងធ្វើឱ្យមានតម្លាភាព។

៩) គ្រប់ក្រសួងស្ថាប័នមានសមត្ថកិច្ចនិងភាគីពាក់ព័ន្ធជួយគាំទ្រដល់រដ្ឋបាលខណ្ឌសែនសុខក្នុងការអនុវត្តប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខដែលបានសម្រេចដាក់ឱ្យប្រើប្រាស់រួចដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន។

៩៩៥៧៨

## សទ្ទានុក្រម

| | |
|---|---|
| **ការអភិវឌ្ឍដី** | សំដៅដល់ការប្តូរប្រភេទនៃការប្រើប្រាស់ដីទៅជាប្រភេទមួយផ្សេងទៀតតាមរយៈការបង្រួមក្បាលដី ការបំបែកក្បាលដី ការកែទម្រង់ដី និងការបង្កើនដង់ស៊ីតេនៃការប្រើប្រាស់ដីសម្រាប់គោលដៅនៃការសាងសង់លំនៅឋាន ពាណិជ្ជកម្ម សេវាកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លម្ហសាធារណៈ និងសេវាសាធារណៈស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី។ |
| **កន្លែងផ្លូវប្រសព្វ** | សំដៅដល់កន្លែងប្រសព្វនៃផ្លូវពីរឬច្រើនដែលមានផ្ទៃរាបតែមួយនិងមិនកំណត់មុំនៃអ័ក្សរបស់ទ្រូងផ្លូវឡើយ។ កន្លែងផ្លូវប្រសព្វអាចមានរាងជា +, X, Y, T ឬរង្វង់មូលជាដើម។ |
| **កន្លែងផ្លូវប្រសព្វក្នុងលម្ហ** | សំដៅដល់កន្លែងប្រសព្វនៃផ្លូវពីរឬច្រើនដែលមានកម្រិតកម្ពស់ផ្ទៃខុសគ្នានិងមិនកំណត់មុំនៃអ័ក្សរបស់ទ្រូងផ្លូវឡើយ។ ផ្លូវប្រសព្វក្នុងលម្ហអាចមានរាងជា +, X, និង *។ |
| **ការកែសម្រួលក្បាលដី** | សំដៅដល់ការរៀបចំក្បាលដីឡើងវិញដើម្បីធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លម្ហសាធារណៈ និងសេវាសាធារណៈដោយមានការចូលរួម ព្រមទាំងបង្កើនលទ្ធភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់ដីស្របតាមបទប្បញ្ញត្តិជាធរមាន។ |
| **ការត្រួតពិនិត្យការអភិវឌ្ឍ** | សំដៅដល់ការត្រួតពិនិត្យការអនុវត្តស្របតាមប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងស្របតាមបទប្បញ្ញត្តិជាធរមាន។ |
| **ការបង្រួមក្បាលដី** | សំដៅដល់ការបញ្ចូលក្បាលដីច្រើនដែលជាប់គ្នាឱ្យក្លាយទៅជាក្បាលដីតែមួយដើម្បីធ្វើផែនការអភិវឌ្ឍទីក្រុងសម្រាប់ធ្វើសមាហរណកម្មនិងធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈនិងសេវាសាធារណៈសំដៅធានាចីរភាព សមធម៌ តុល្យភាព សុខភាព និងភាពងាយស្រួលនៃទីក្រុង។ |
| **ការប្តូរប្រភេទនៃការប្រើប្រាស់ដី** | សំដៅដល់ការផ្លាស់ប្តូរការប្រើប្រាស់ដីពីប្រភេទមួយទៅប្រភេទផ្សេងទៀតស្របតាមបទប្បញ្ញត្តិជាធរមាន។ |
| **ការបំបែកក្បាលដី** | សំដៅដល់ការបំបែកក្បាលដីតែមួយទៅជាក្បាលដីច្រើនសម្រាប់ការសាងសង់លំនៅឋាន ពាណិជ្ជកម្ម ឧស្សាហកម្ម។ល។ ដោយធានាបាននូវការរៀបចំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ លម្ហសាធារណៈ និងសេវាសាធារណៈស្របតាមបទប្បញ្ញត្តិនៃការប្រើប្រាស់ដី។ |
| **ការរៀបចំដែនដី** | សំដៅដល់ការកំណត់ការប្រើប្រាស់ដីក្នុងកម្រិតម៉ាក្រូដោយយោងលើលក្ខខណ្ឌភូមិសាស្ត្រនិងសក្តានុពលនៃតំបន់នីមួយៗដើម្បីធានាការការពារ ការអភិរក្ស និងការអភិវឌ្ឍប្រកបដោយចីរភាព សមធម៌ និងប្រសិទ្ធភាព។ ការរៀបចំដែនដីធ្វើឡើងដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ធានាសន្តិសុខស្បៀង កិច្ចការពារជាតិ លំនឹងធម្មជាតិ និងតម្រង់ទិសដល់ការអភិវឌ្ឍជាតិឱ្យមានតុល្យភាពនៅទូទាំងប្រទេសលើផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សង្គម សេដ្ឋកិច្ច និងបរិស្ថាន ព្រមទាំងការធ្វើសមាហរណកម្មនៅក្នុងប្រទេស ក្របខណ្ឌតំបន់ និងអន្តរជាតិ។ |

| | |
|---|---|
| **ខ្សែបន្ទាត់ព្រំដីចំណីផ្លូវថ្នល់** | សំដៅដល់ខ្សែបន្ទាត់នៃបណ្តាចំណុចព្រំដីចំណីផ្លូវដែលមានចម្ងាយកំណត់ពីខ្សែបន្ទាត់ផ្ចិតនៃផ្លូវថ្នល់។ |
| **គន្លងផ្លូវ** | សំដៅដល់ចំណែកមួយនៃទ្រូងផ្លូវខណ្ឌដោយគំនូសឬបរិក្ខារបែងចំណែកផ្លូវតាមបណ្តោយទ្រូងផ្លូវដែលមានទទឹងគ្រប់គ្រាន់អាចឱ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍បានមួយជួរ។ |
| **ចិញ្ចើមផ្លូវ** | សំដៅដល់ផ្នែកសងខាងនៃទ្រូងផ្លូវនៅក្នុងទីប្រជុំជនដែលរៀបចំទុកសម្រាប់ថ្មើរជើងធ្វើដំណើរ ដាំដើមឈើ និងបង្កប់បរិក្ខារបម្រើផលប្រយោជន៍សេវាសាធារណៈ។ |
| **ជាយផ្លូវ** | សំដៅដល់ផ្នែកសងខាងនៃទ្រូងផ្លូវនៅក្រៅទីប្រជុំជនដែលយានជំនិះអាចចតបានក្នុងករណីចាំបាច់។ |
| **ដង់ស៊ីតេប្រជាជន** | សំដៅដល់អនុបាតរវាងចំនួនប្រជាជននិងផ្ទៃក្រឡាដីក្នុងវិសាលភាពជាក់លាក់ណាមួយ។ |
| **ដីចំណីផ្លូវថ្នល់** | សំដៅដល់ដីនៅសងខាងខ្សែបន្ទាត់ផ្ចិតនៃផ្លូវថ្នល់និងទំហំចំណីផ្លូវថ្នល់ទុកបម្រុងសម្រាប់ការគ្រប់គ្រង ការអភិវឌ្ឍ ការការពារផ្លូវថ្នល់ ធានាសុវត្ថិភាពចរាចរណ៍ និងការប្រើប្រាស់ការងារហេដ្ឋារចនាសម្ព័ន្ធបវន្តផ្សេងទៀតដែលកំណត់ដោយខ្សែបន្ទាត់ព្រំដីចំណីផ្លូវ។ |
| **តំបន់កសិកម្ម** | សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់វិស័យកសិកម្មដូចជាវាលស្រែ ចម្ការ សួនបន្លែ កសិដ្ឋានចិញ្ចឹមសត្វ ថ្នាលបណ្តុះកូនឈើ កន្លែងចិញ្ចឹមត្រី បង្គារ ក្តាម សិប្បកម្មបម្រើដល់កសិកម្ម។ល។ តំបន់នេះអាចសាងសង់លំនៅឋានរបស់កសិករ។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| **តំបន់ការពារ** | សំដៅដល់តំបន់ធម្មជាតិនិងទស្សនីយភាពដែលត្រូវការពារដើម្បីបម្រើឱ្យវិស័យបរិស្ថាន សេដ្ឋកិច្ច សង្គមកិច្ច វិទ្យាសាស្ត្រ ការអប់រំ និងការកម្សាន្តដូចជាឆ្នេរសមុទ្រ ចំណីទន្លេ ភ្នំឧទ្យានជាតិ តំបន់ដីសើម តំបន់ជីវចម្រុះជាតិ។ល។ |
| **តំបន់ចម្រុះ** | សំដៅដល់តំបន់ដែលអាចប្រើប្រាស់ពហុមុខងារសម្រាប់លំនៅឋាន ពាណិជ្ជកម្ម និងសេវាកម្មដោយធានាបានបរិស្ថានរស់នៅដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| **តំបន់ដឹកជញ្ជូន** | សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់អគារហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មបម្រើដល់វិស័យដឹកជញ្ជូននិងគមនាគមន៍មានជាអាទិ៍ស្ថានីយរថភ្លើង ព្រលានយន្តហោះ ស្ថានីយរថយន្ត កំពង់ចម្លង កំពង់ផែ ផែស្ងួត ឃ្លាំង មជ្ឈមណ្ឌលចែកចាយទំនិញនិងភស្តុភារកម្ម និងមជ្ឈមណ្ឌលទូរគមនាគមន៍។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |

| | |
|---|---|
| **តំបន់ទេសចរណ៍** | សំដៅដល់តំបន់សម្រាប់សាងសង់អគារបម្រើដល់វិស័យទេសចរណ៍និងកម្សាន្ត រួមមានសណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន កន្លែងកម្សាន្ត។ល។ |
| **តំបន់ធនធានទឹក** | សំដៅដល់តំបន់ផ្ទៃទឹកនិងប្រភពទឹកដែលត្រូវថែរក្សានិងការពារដូចជាសមុទ្រ ទន្លេ ព្រែក ស្ទឹង អូរ ប្រឡាយ បឹង ទំនប់ សំណង់ធារាសាស្ត្រ។ល។ |
| **តំបន់ពាណិជ្ជកម្ម** | សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យពាណិជ្ជកម្ម ធុរកិច្ច និងសេវាកម្មនានាដូចជាអគារការិយាល័យ ធនាគារ រោងកុន រោងល្ខោន ភោជនីយដ្ឋាន សណ្ឋាគារ ហាងលក់ដូរ ទីផ្សារ និងដេប៉ូចែកចាយទំនិញ ។ល។ ដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| **តំបន់ពាណិជ្ជកម្មចម្រុះ** | សំដៅដល់តំបន់ដែលមានមុខងារពាណិជ្ជកម្មសម្រាប់បម្រើដល់លំនៅឋាននិងការស្នាក់នៅដូចជាហាងលក់ដូរនិងទីផ្សារតូចៗដែលលក់ដូរទំនិញនិងសេវាកម្មដើម្បីផ្គត់ផ្គង់និងគាំទ្រដល់ការរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋានប្រចាំថ្ងៃដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| **តំបន់ព្រៃឈើ** | សំដៅដល់តំបន់ផ្ទៃព្រៃឈើនិងគម្របព្រៃឈើដែលត្រូវការពារ ថែរក្សា និងដាំបន្ថែម ដូចជាព្រៃស្រោង ព្រៃរបោះ ព្រៃការពារ ព្រៃអភិរក្ស ព្រៃលិចទឹក។ល។ |
| **តំបន់រដ្ឋបាលនិងសេវាសាធារណៈ** | សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យរដ្ឋបាលនិងសេវាសាធារណៈដូចជាទីស្តីការក្រសួង ស្ថាប័ន មន្ទីរ អង្គភាព សាលារាជធានី សាលាខេត្ត សាលាក្រុង សាលាស្រុក ខណ្ឌ សាលាឃុំ សង្កាត់ សាលារៀន មន្ទីរពេទ្យ បណ្ណាល័យ មណ្ឌលសុខភាព ប្រៃសណីយ៍។ល។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| **តំបន់លំនៅឋានកម្ពស់ខ្ពស់** | សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានកម្ពស់ខ្ពស់ដូចជាអគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| **តំបន់លំនៅឋានកម្ពស់មធ្យម** | សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានកម្ពស់មធ្យមដូចជាភូមិគ្រឹះទោល ភូមិគ្រឹះភ្លោះ ផ្ទះល្វែង ផ្ទះល្វែងភ្លោះ អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| **តំបន់លំនៅឋានចម្រុះ** | សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានច្រើនប្រភេទ ដូចជាលំនៅឋានជាប់គ្នា លំនៅឋានពាក់កណ្ដាលជាប់គ្នា លំនៅឋានដាច់ពីគ្នា អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |

| | |
|---|---|
| តំបន់លំនៅឋានជាប់គ្នាកម្ពស់ទាប | សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដែលមានជញ្ជាំងជាប់គ្នាដែលមានកម្ពស់ទាបដូចជាផ្ទះល្វែង ផ្ទះល្វែងភ្ជោះ អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| តំបន់លំនៅឋានដាច់ពីគ្នាកម្ពស់ទាប | សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់អគារលំនៅឋានដាច់ពីគ្នាឬជាប់គ្នាមួយចំហៀងដែលមានកម្ពស់ទាបដូចជាភូមិគ្រឹះទោល ភូមិគ្រឹះភ្លោះ ផ្ទះក្នុងដីឡូត៍ដែលមានផ្លាគម្លាតជុំវិញ អគារស្នាក់នៅ អគារលំនៅឋានសហកម្មសិទ្ធិដែលមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង | សំដៅដល់តំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលម្ហែ ការកម្សាន្តនិងពិធីសាធារណៈនានាដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេងសួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់សម្រាប់បម្រើដល់សាធារណជន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| តំបន់វប្បធម៌និងសាសនា | សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យប្រវត្តិសាស្ត្រ សិល្បៈ វប្បធម៌ និងសាសនាដូចជាប្រាសាទ វត្តអារាម វិហារសាសនា សាលារៀន សារមន្ទីរ ទីលានកីឡា កន្លែងសិប្បកម្មចម្លាក់ សាលាឆទានពុទ្ធិកសាកលវិទ្យាល័យ។ល។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| តំបន់ស្នូលនៃការអភិវឌ្ឍ | សំដៅដល់តំបន់ដែលមានសក្តានុពលខ្ពស់ឬតំបន់ដែលមានការអភិវឌ្ឍខ្ពស់សម្រាប់គាំទ្រដល់តំបន់ដែលមានសក្តានុពលទាប។ |
| តំបន់ឧស្សាហកម្ម | សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មខ្នាតធំដែលមានជាតិពុលខ្ពស់ដូចជារោងចក្រ រោងសិប្បកម្មខ្នាតធំ ឃ្លាំងយានដ្ឋាន។ល។ ហើយមិនអនុញ្ញាតឱ្យសាងសង់លំនៅឋាននៅតំបន់នេះឡើយ។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |
| តំបន់ឧស្សាហកម្មចម្រុះ | សំដៅដល់តំបន់ដែលមានមុខងារចម្បងសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មនិងសេវាកម្ម។ គ្រប់អគាររោងចក្រទាំងអស់ត្រូវបានអនុញ្ញាតឱ្យសាងសង់លើកលែងតែអគារដែលមានផលប៉ះពាល់បរិស្ថានខ្ពស់។ តំបន់នេះអាចអនុញ្ញាតឱ្យមានលំនៅឋាននិងអគារពាណិជ្ជកម្មដូចជាសាលារៀន មន្ទីរពេទ្យ សាកលវិទ្យាល័យ ភោជនីយដ្ឋាន រោងកុន ឃ្លាំង យានដ្ឋាន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។ |

**តំបន់ឧស្សាហកម្មស្រាល** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់សាងសង់សំណង់ដែលបម្រើដល់វិស័យឧស្សាហកម្មខ្នាតតូចដែលមានជាតិពុលតិចឬមធ្យមដូចជារោងចក្រ រោងសិប្បកម្មខ្នាតតូច ឃ្លាំង យានដ្ឋាន។ល។ ហើយអាចអនុញ្ញាតឱ្យសាងសង់លំនៅឋាននៅតំបន់នេះបាន។ តំបន់នេះមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងដីឡូត៍ និងមានសន្ទស្សន៍ប្រើប្រាស់ដីកំណត់ដោយអនុក្រឹត្យ។

**ទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យាន** សំដៅដល់ផលបូកទម្ងន់យាននិងទម្ងន់ផ្ទុកមនុស្សនិងទម្ងន់ផ្ទុកទំនិញ។ ប្រសិនបើយានមានសណ្ដោង ទម្ងន់សរុបអនុញ្ញាតអតិបរមារបស់យានគឺផលបូកនៃទម្ងន់សរុបអតិបរមារបស់យាននីមួយៗ។

**ទីក្រុង** សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូចស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធរូបវន្តទីក្រុង។ល។

**ទីតាំងសម្រាកលំហែ** សំដៅដល់កន្លែងសម្រាប់ធ្វើសេវាកម្មសាធារណៈដែលស្ថិតនៅខាងក្រៅដីចំណីផ្លូវនៃផ្លូវថ្នល់ធំៗដូចជាផ្លូវល្បឿនលឿន ផ្លូវជាតិសម្រាប់ឱ្យអ្នកបើកបរនិងអ្នកធ្វើដំណើរឈប់សម្រាកដោយមានសណ្ឋាគារ ភោជនីយដ្ឋាន បណ្ដាញផ្លូវថ្នល់សុវត្ថិភាព ចំណតរថយន្ត ស្ថានីយប្រេងឥន្ធនៈ ស្ថានីយផ្ដល់ព័ត៌មាន យានដ្ឋានជួសជុលយានយន្ត បណ្ដាញទឹកស្អាត ប៉ុន្តែមិនមែនជារមណីយដ្ឋានទេ។

**ទឹកកខ្វក់** សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់រួចមានដូចជាទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួមទាំងទឹកនោមនិងលាមកដែលបញ្ចេញពីលំនៅឋានបុរីលំនៅឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និងតំបន់រមណីយដ្ឋានឬមជ្ឈមណ្ឌលកម្សាន្ត។

**ទឹកក្រោមដី** សំដៅដល់ទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំនិងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។

**ទ្រូងផ្លូវ** សំដៅដល់ចំណែកនៃផ្លូវដែលទុកសម្រាប់ឱ្យយានជំនិះគ្រប់ប្រភេទធ្វើចរាចរណ៍។

**ទំហំផ្លូវកម្រិតកំណត់** សំដៅដល់ទំហំមានខ្នាតកម្រិតកំណត់អំពីកម្ពស់និងផ្ទៃរបស់ផ្លូវ ស្ពាន កំពង់ចម្លង ផ្លូវរូង។ល។ ដើម្បីឱ្យរថយន្តដឹកជញ្ជូនទំនិញឆ្លងកាត់មានសុវត្ថិភាព។

**នគរូបនីយកម្ម** សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រងការអភិវឌ្ឍ ការសាងសង់ និងការកែលម្អនៅក្នុងទីក្រុងនិងតំបន់ជុំវិញ ព្រមទាំងតំបន់ទទួលឥទ្ធិពលក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភ័ណភាព សមធម៌ និងសមាហរណកម្ម។

| | |
|---|---|
| បទដ្ឋានទំហំដីឡូត៍បច្ចេកទេស | សំដៅដល់ទំហំដីឡូត៍ដែលកំណត់ដោយប្រវែងក្បាលដីនិងជម្រៅដី ហើយត្រូវបានកំណត់ឡើងដើម្បីធានាការរៀបចំ ការគ្រប់គ្រងទីក្រុង ការអភិវឌ្ឍទីក្រុង ការអភិវឌ្ឍរចនាសម្ព័ន្ធ និងការអភិវឌ្ឍដីឱ្យមានសោភ័ណភាពនិងមានសណ្តាប់ធ្នាប់។ |
| បទប្បញ្ញត្តិបច្ចេកទេស | សំដៅដល់បទដ្ឋានបច្ចេកទេស ស្តង់ដាបច្ចេកទេស និងឯកសារណែនាំលម្អិតបច្ចេកទេស ការងារ លក្ខខណ្ឌសុវត្ថិភាពការងារ និងលក្ខខណ្ឌសុវត្ថិភាពចរាចរណ៍។ |
| បរិក្ខារបែងចែកចំណែកផ្លូវ | សំដៅដល់បរិក្ខារសម្រាប់បែងចែកចំណែកទ្រូងផ្លូវជាពីរចំណែកឱ្យចរាចរណ៍ទៅមក ឬបែងចែកចំណែកនោះជាគន្លងផ្លូវ។ បរិក្ខារបែងចែកចំណែកផ្លូវមានជាប្រភេទចល័ត និងអចល័ត។ |
| បរិក្ខារផ្លូវថ្នល់ | សំដៅដល់ទីចំណត ទីស៊ីចត ភ្លើងសញ្ញា ផ្លាកសញ្ញាកំណត់ល្បឿន ផ្លាកសញ្ញាបង្ហាញផ្លូវ សញ្ញាចន្លោះគម្លាត គំនូសសញ្ញាឬរបាំងឬបរិក្ខារបែងចែកចំណែកផ្លូវរង្វង់មូល ខឿនបែងចែកទិសចរាចរណ៍ ថ្មចិញ្ចើមផ្លូវ ជញ្ជាំង របងការពារ បង្គោលគីឡូម៉ែត្រ បង្គោលសញ្ញាកំណត់ព្រំ ព្រមទាំងផ្លាកសញ្ញានិងឧបករណ៍បំពាក់ផ្សេងទៀតនៅតាមបណ្តោយផ្លូវថ្នល់។ |
| បរិក្ខារសម្រួលការបង្ហូរទឹក | សំដៅដល់ប្រឡាយ ស្នាមភ្លោះ អាងស្តុកទឹក ស្ថានីយចម្រោះទឹកកខ្វក់ ទីជម្រាលឬចំណោត។ល។ ដែលបានរៀបចំនៅតាមបណ្តោយផ្លូវថ្នល់សម្រាប់ការពារផ្លូវថ្នល់ បរិក្ខារផ្លូវថ្នល់ និងសុវត្ថិភាពចរាចរណ៍។ |
| បឹងបួ | សំដៅដល់ល្ហាលទឹកធំល្វឹងល្វើយកើតពីទីជម្រាលឬជម្រៅធម្មជាតិដែលអាចមានទឹក ឬគ្មានទឹកទៅតាមរដូវកាលនិងមានប្រភពមកពីទន្លេ ស្ទឹង ព្រែកឬពីតំបន់ផ្ទៃរងទឹកភ្លៀង។ |
| ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ | សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយបូមលូឬទឹកភ្លៀង បណ្តាញលូមេ បណ្តាញលូមេរង ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួមមានតាមលក្ខណៈបច្ចេកវិទ្យាឬលក្ខណៈធម្មជាតិ។ |
| ប្រព័ន្ធលូ | សំដៅដល់បណ្តាញប្រមូលនិងបង្ហូរទឹកកខ្វក់រួមមានតំណភ្ជាប់ អណ្តូងលូ និងបណ្តាញលូ (បណ្តាញលូរួម បណ្តាញលូដាច់ដោយឡែក បណ្តាញលូមេ បណ្តាញលូមេរង បណ្តាញលូខ្នែង និងបណ្តាញលូខ្នែងរង)។ |
| ប្រភេទដីកម្រិតការសាងសង់ | សំដៅដល់ប្រភេទដីដែលត្រូវគ្រប់គ្រងពិសេសចំពោះការសាងសង់។ ប្រភេទដីនេះត្រូវបានបែងចែកជាតំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។ |
| ប្រភេទដីអាចសាងសង់បាន | សំដៅដល់ប្រភេទដីដែលជំរុញឱ្យមានការអភិវឌ្ឍនិងការសាងសង់លើគ្រប់វិស័យ។ ប្រភេទដីនេះត្រូវបានបែងចែកជាតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាសាធារណៈ តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។ |

| | |
|---|---|
| ប្លង់គោលប្រើប្រាស់ដី ឬប្លង់គោល | សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្រសរុបសម្រាប់ការអភិវឌ្ឍរូបវន្តនិងកំណត់ពីប្រភេទនៃការប្រើប្រាស់ដី (ប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់) ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុង បណ្ដាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងគមនាគមន៍សំខាន់ៗនៃទីក្រុង ព្រមទាំងការធ្វើសមាហរណកម្ម។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍនិងអភិរក្សទីក្រុងទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ប្លង់គោលប្រើប្រាស់ដីគឺជាប្លង់ដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។ |
| ប្លង់ទ្រេត | សំដៅដល់ប្លង់សម្រាប់កំណត់កម្ពស់អតិបរមានៃសំណង់។ ប្លង់នេះត្រូវបានកំណត់ឡើងដោយសមាមាត្រនៃទំហំទទឹងផ្លូវនិងការថយឆ្ងាតគម្លាតនៃអគារជាមួយនឹងកម្ពស់អគារដើម្បីធានាឱ្យមានចរន្តពន្លឺ ចរន្តខ្យល់ និងបរិស្ថានរស់នៅល្អពីអគារមួយទៅអគារមួយទៀត ព្រមទាំងធានាភាពសុខដុមនីយកម្មនៃស្ថាបត្យកម្មក្នុងតំបន់និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។ |
| ប្លង់លម្អិតនគរូបនីយកម្ម | សំដៅដល់ប្លង់វិលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុងឬជាគម្រោងអភិវឌ្ឍទីក្រុងដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបបន្តលម្អិតនៃការរៀបចំផ្នែក ទីតាំងឬតំបន់ប្រើប្រាស់ដីណាមួយឬច្រើនទីក្រុងដែលរួមមានការបង្ហាញអំពីការរៀបចំ ការរចនាទម្រង់ រូបរាងនិងសោភ័ណភាពនៃរចនាសម្ព័ន្ធរូបវន្តសម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់តាមរយៈគំនូរឬរូបសំណាក។ ប្លង់លម្អិតនគរូបនីយកម្មត្រូវគោរពតាមផែនការប្រើប្រាស់ដី។ |
| ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ | សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដីនិងផ្ទៃក្រឡាដីឡូត៍គិតជាភាគរយ។ |
| ផែនការប្រើប្រាស់ដី | សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដីដែលកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ជានៃការប្រើប្រាស់ដីជាក់ស្ដែងការសាងសង់ ការអភិវឌ្ឍដី និងការអភិរក្សក្នុងតំបន់នីមួយៗ ព្រមទាំងកំណត់អំពីបណ្ដាញគមនាគមន៍និងការធ្វើសមាហរណកម្ម។ ផែនការប្រើប្រាស់ដីគឺជាផែនការដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។ |
| ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ | សំដៅដល់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋនិងទាំងដីឯកជនរបស់បុគ្គលឯកជនដោយប៉ាន់ប្រមាណពីសក្ដានុពលដីនិងធនធានទឹក និងលទ្ធភាពផ្សេងៗក្នុងការប្រើប្រាស់ដី ព្រមទាំងលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គមកិច្ចដើម្បីធ្វើការជ្រើសរើសនូវជម្រើសសមស្របក្នុងការប្រើប្រាស់ដី។ |

| | |
|---|---|
| ផែនការរូបវន្តទីក្រុង | សំដៅដល់ការធ្វើសមាហរណកម្មផែនការប្រើប្រាស់ដី និងផែនការហេដ្ឋារចនាសម្ព័ន្ធរូបវន្តដើម្បីធានាការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់ក្នុងទីក្រុងឱ្យមានចីរភាព តុល្យភាព សុខុមាលភាព សោភ័ណភាព និងសមធម៌។ ផែនការរូបវន្តទីក្រុងមានប្លង់គោលប្រើប្រាស់ដីឬប្លង់គោល ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។ |
| ផែនការរៀបចំដែនដី | សំដៅដល់ផែនការដែលកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រតម្រង់ទិសការប្រើប្រាស់ដី និងការអភិវឌ្ឍផ្ទៃរូបវន្តដោយផ្អែកលើសក្តានុពលនៃភូមិសាស្ត្រនិងតំបន់នីមួយៗ ក្នុងក្របខណ្ឌថ្នាក់ជាតិ តាមតំបន់ និងថ្នាក់ខេត្ត។ |
| ផ្លូវខេត្ត | សំដៅដល់ផ្លូវដែលមានចរាចរណ៍មធ្យមរួមមាន៖ ក-ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ ខ-ផ្លូវបែកចេញពីផ្លូវជាតិឆ្ពោះទៅកាន់ផ្លូវខេត្ត គ-ផ្លូវបែកចេញពីផ្លូវខេត្តឬផ្លូវក្រុងឆ្ពោះទៅកាន់ទីរួមស្រុក ខណ្ឌ ឃ-ផ្លូវបែកចេញពីក្រុងនៃខេត្តឆ្ពោះទៅកាន់ផ្លូវខេត្ត ង-ផ្លូវបែកចេញពីផ្លូវខេត្តឆ្ពោះទៅកាន់ផ្លូវខេត្ត និង ច-ផ្លូវបែកចេញពីផ្លូវខេត្តឬផ្លូវក្រុងឬផ្លូវទីប្រជុំជននានាក្នុងខេត្តឆ្ពោះទៅកាន់តំបន់សំខាន់ៗដូចជាកំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារព្រំដែនទ្វេភាគី និងតំបន់មានសក្តានុពលសេដ្ឋកិច្ចមធ្យមផ្សេងទៀត។ |
| ផ្លូវជនបទ | សំដៅដល់៖ ក-ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ ទីប្រជុំជនឃុំ សង្កាត់ និងទៅភូមិ ខ-ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌឆ្ពោះទៅកាន់ក្រុង ទីរួមស្រុក ខណ្ឌ គ-ផ្លូវដែលភ្ជាប់ពីក្រុង ទីរួមស្រុក ខណ្ឌឆ្ពោះទៅទីប្រជុំជនឃុំ សង្កាត់ ឃ-ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ឆ្ពោះទៅទីប្រជុំជនឃុំ សង្កាត់ ង-ផ្លូវដែលភ្ជាប់ពីទីប្រជុំជនឃុំ សង្កាត់ឆ្ពោះទៅភូមិ ច-ផ្លូវដែលភ្ជាប់ពីភូមិទៅភូមិ និង ឆ-ផ្លូវក្នុងភូមិ។ |
| ផ្លូវជាតិ | សំដៅដល់ផ្លូវដែលមានចរាចរណ៍ច្រើនរួមមាន៖ ក-ផ្លូវភ្ជាប់ចេញពីរាជធានីភ្នំពេញឆ្ពោះទៅកាន់ក្រុងនៃខេត្តនីមួយៗនៅទូទាំងប្រទេស ខ-ផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយទៀត គ-ផ្លូវភ្ជាប់ចេញពីផ្លូវជាតិឆ្ពោះទៅកាន់ផ្លូវជាតិ ឃ-ផ្លូវបែកចេញពីផ្លូវជាតិឆ្ពោះទៅកាន់ក្រុងនៃខេត្តមួយ ង-ផ្លូវបែកចេញពីផ្លូវជាតិឬផ្លូវភ្ជាប់ចេញពីក្រុងនៃខេត្តមួយឆ្ពោះទៅកាន់តំបន់សំខាន់ៗដូចជាកំពង់ផែ ស្ថានីយរថភ្លើង អាកាសយានដ្ឋាន តំបន់សេដ្ឋកិច្ចពិសេស រមណីយដ្ឋានទេសចរណ៍ ច្រកទ្វារព្រំដែន តំបន់មានសក្តានុពលសេដ្ឋកិច្ចសំខាន់ៗផ្សេងទៀត និង ច-ផ្លូវសំខាន់ៗរបស់ជាតិមានចរាចរណ៍ច្រើនដែលកំណត់ដោយរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន។ |
| ផ្លូវជាន់គ្នា | សំដៅដល់ផ្លូវពីរឬច្រើនស្ថិតនៅលើផ្ទៃរាបតែមួយឬស្ថិតនៅលើផ្ទៃខុសកម្រិតគ្នា មានទិសស្របគ្នា មានប្រភេទនិងមុខងារផ្លូវខុសគ្នា។ |

| | |
|---|---|
| ផ្លូវថ្នល់ ឬផ្លូវ | សំដៅដល់ទំហំផ្លូវទាំងមូលរួមមានតួផ្លូវ ទ្រូងផ្លូវ ជាយផ្លូវឬចិញ្ចើមផ្លូវ ស្ពាន ស្ពានអាកាស ស្ពានវិលង ផ្លូវរូង និងកំពង់ចម្លងតភ្ជាប់ផ្លូវថ្នល់។ |
| ផ្លូវថ្មើរជើង | សំដៅដល់ផ្នែកមួយនៃផ្លូវថ្នល់ដែលធ្វើឬរៀបចំឡើងសម្រាប់ឱ្យមនុស្សដើរប្រកបដោយសុវត្ថិភាព។ |
| ផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីប្រជុំជននានាក្នុងខេត្ត | សំដៅដល់ផ្លូវថ្នល់ដែលស្ថិតនៅក្នុងបរិវេណភូមិសាស្ត្ររដ្ឋបាលរាជធានី ខេត្តរួមមានទ្រូងផ្លូវ ចិញ្ចើមផ្លូវ និងផ្លូវថ្មើរជើង។ |
| ផ្លូវរូង | សំដៅដល់ខ្សែផ្លូវបម្រើឱ្យចរាចរណ៍ ស្ថិតនៅក្រោមផ្ទៃដីឬក្នុងរូងដែលមានជញ្ជាំងសុវត្ថិភាព។ |
| ផ្លូវល្បឿនលឿន | សំដៅដល់ផ្លូវសម្រាប់យានយន្តធ្វើចរាចរណ៍ មានបរិក្ខារចែកទ្រូងផ្លូវជាពីរចំណែកខុសទិសគ្នាឬចែកជាគន្លងផ្លូវ គ្មានកន្លែងផ្លូវប្រសព្វលើផ្ទៃរាបមួយឬត្រូវមានផ្លូវប្រសព្វតិចបំផុតក្នុងករណីចាំបាច់ និងបំពាក់គ្រប់គ្រាន់នូវបរិក្ខារផ្លូវថ្នល់ដើម្បីធានាលំហូរចរាចរណ៍អត់ឈប់ សុវត្ថិភាព និងបន្ថយពេលវេលាធ្វើដំណើរនិងមានកន្លែងកំណត់សម្រាប់ឱ្យយានយន្តចេញនិងចូលផ្លូវល្បឿនលឿន។ |
| មន្ត្រីមានសមត្ថកិច្ច | សំដៅដល់មន្ត្រីថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ |
| ម្ចាស់សំណង់ | សំដៅដល់ម្ចាស់សិទ្ធិលើអគារឬសំណង់។ |
| ម្ចាស់សំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុ | សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលបានលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។ |
| រង្វង់មូល | សំដៅដល់កន្លែងផ្លូវប្រសព្វដែលនៅចំកណ្ដាលមានខឿនជារាងរង្វង់មូល មានផ្លាកសញ្ញាបង្ហាញទិសចរាចរណ៍ និងមានទ្រូងផ្លូវឯកទិសព័ទ្ធជុំវិញដោយសញ្ញាព្រួញប្រាប់ទិសចរាចរណ៍។ |
| លម្ហសាធារណៈ និងផ្ទៃបៃតង | សំដៅដល់ចំណែកធ្លាមួយមិនមានអគារឬរចនាសម្ព័ន្ធត្រូវបានសាងសង់ផ្សេងទៀត និងអាចដំណើរការជាសាធារណៈរួមមានៈ ១)លម្ហបៃតងដីដែលត្រូវបានគ្របដណ្ដប់មួយផ្នែកឬទាំងស្រុងដោយស្មៅ ដើមឈើ រុក្ខជាតិឬបន្លែផ្សេងទៀត។ ទីធ្លាបៃតងមានរួមបញ្ចូលទាំងសួនកុមារ ឧទ្យាន សួនច្បារសហគមន៍ និងទីលានបញ្ចុះសព ២)កន្លែងអង្គុយឬទីធ្លាទំនេរក្នុងតំបន់សាធារណៈ ៣)តំបន់ព្រៃដូចជាព្រៃបម្រុងទុកអចិន្ត្រៃយ៍ ព្រៃឯកជន និងព្រៃលិចទឹក និង ៤)ផ្ទៃទឹក ទន្លេ បឹង ស្ទឹង អូរ ប្រឡាយ។ល។ ជាទូទៅលម្ហសាធារណៈនិងផ្ទៃបៃតងផ្ដល់នូវតំបន់កម្សាន្តសម្រាប់ប្រជាជនទូទៅដើម្បីបង្កើនភាពស្រស់ស្អាតនិងគុណភាពបរិស្ថាន។ |
| សន្ទស្សន៍ប្រើប្រាស់ដី | សំដៅដល់អនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្ទៃការ និងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះតាំងនៅ។ |
| ស្ថានីយចំណតរថយន្ត | សំដៅដល់កន្លែងចតរថយន្តសម្រាប់សកម្មភាពឡើងចុះអ្នកដំណើរនិងលើកដាក់ទំនិញ។ |

| | |
|---|---|
| ស្ថានីយថ្លឹងយានយន្ត | សំដៅដល់កន្លែងរៀបចំឡើងសម្រាប់ត្រួតពិនិត្យទម្ងន់យានយន្ត។ |
| ស្ថានីយសេវាតាមដងផ្លូវ | សំដៅដល់កន្លែងបម្រើដល់ចរាចរណ៍តាមដងផ្លូវដូចជាស្ថានីយប្រេងឥន្ធនៈ កន្លែងគ្រប់គ្រងនិងផ្តល់ព័ត៌មាន ទីតាំងសម្រាកលំហែ យានដ្ឋានជួសជុលយានយន្ត។ល។ |
| ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ | សំដៅដល់រោងចក្រសម្អាតទឹកកខ្វក់រួមរបស់ទីប្រជុំជន រាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ។ |
| ស្ថានីយសម្រាក | សំដៅដល់កន្លែងសម្រាប់ឱ្យអ្នកធ្វើដំណើរសម្រាកដោយមានសេវាអាហារដ្ឋាន បង្គន់អនាម័យ កន្លែងជូនដំណឹង។ល។ |
| ស្ពាន | សំដៅដល់សំណង់ឆ្លងផ្ទៃទឹកសម្រាប់ចម្លងចរាចរណ៍ពីទីតាំងមួយទៅទីតាំងមួយទៀត។ |
| ស្ពានវិលង | សំដៅដល់ស្ពានឆ្លងផ្ទៃដីសម្រាប់ចម្លងចរាចរណ៍ពីទីតាំងមួយទៅទីតាំងមួយទៀតដោយវិលងផ្លូវថ្នល់ឬផ្លូវរថភ្លើងនៅទីតាំងតែមួយ។ |
| ស្ពានអាកាស | សំដៅដល់ស្ពានឆ្លងផ្ទៃដីសម្រាប់ចម្លងចរាចរណ៍ពីទីតាំងមួយទៅទីតាំងមួយទៀតដោយវិលងសំណង់គ្រប់ប្រភេទនៅទីតាំងខុសៗគ្នានិងកម្រិតកម្ពស់ខុសៗគ្នា។ |
| សំណង់ផ្លូវថ្នល់ | សំដៅដល់ផ្លូវថ្នល់ កន្លែងឈប់យានជំនិះ ចំណតរថយន្តលើផ្លូវ បរិក្ខារផ្លូវថ្នល់ សំណង់សិល្បការ្យ និងសំណង់ផ្សេងៗទៀតបម្រើឱ្យផ្លូវថ្នល់។ |
| សំណង់សិល្បការ្យ | សំដៅដល់សំណង់ស្ពាន លូ ជញ្ជាំងទប់ដី ប្រព័ន្ធរំដោះទឹក និងសំណង់រូបវន្តផ្សេងទៀតដែលផ្តល់នូវសុវត្ថិភាព ប្រសិទ្ធភាព និងស្ថិរភាពដល់ផ្លូវថ្នល់។ |
| សំណល់រាវ | សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាពឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្មឬសេវាកម្ម។ |
| សំណៅ | សំដៅដល់ការចម្លងពីសេចក្តីដើមឬច្បាប់ដើមដើម្បីទុកជាឯកសារ។ |
| ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ | សំដៅដល់ដីចំណីផ្លូវ សំណង់ផ្លូវថ្នល់ ស្ថានីយចំណតរថយន្ត បរិវេណចំណតរថយន្ត ទីសុំចតរថយន្ត ស្ថានីយសេវាតាមដងផ្លូវ និងទីតាំងសម្រាកលំហែ។ |
| ទន្លេ | សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅសមុទ្រ។ |
| អាងទន្លេ | សំដៅដល់តំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរ ដោយរាប់បញ្ចូលទាំងទឹកលើដីនិងទឹកក្រោមដី។ |
| អាងទឹក | សំដៅដល់ទីតម្កល់ទឹកដែលកើតឡើងដោយធម្មជាតិឬសិប្បនិម្មិតសម្រាប់ប្រើទៅតាមតម្រូវការ។ |
| អាងបង្គន់អនាម័យ | សំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យនិងបន្ទប់ទឹកដើម្បីស្តុកនិងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់មុនការហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ។ |
| អាជ្ញាធរមានសមត្ថកិច្ច | សំដៅដល់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌដែលមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ស្របតាមសមត្ថកិច្ច។ |

**អូរ** សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីជ្រោះនិងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចូលព្រែក ស្ទឹង ទន្លេឬបឹង។

**អ្នកជាប់ពាក់ព័ន្ធផ្លូវថ្នល់** សំដៅដល់អ្នកគ្រប់គ្រង អ្នកសាងសង់ អ្នកត្រួតពិនិត្យ អ្នកផ្តល់ហិរញ្ញប្បទានឬសម្បទានិកអភិវឌ្ឍនិងថែទាំផ្លូវថ្នល់ អ្នកដឹកជញ្ជូន និងអ្នកប្រើប្រាស់ផ្លូវថ្នល់ អ្នករស់នៅសងខាងផ្លូវថ្នល់ និងអ្នកផ្គត់ផ្គង់សម្ភារៈគ្រឿងចក្រនិងបរិក្ខារផ្លូវថ្នល់។

**អ្នកប្រើប្រាស់ផ្លូវថ្នល់** សំដៅដល់អ្នកបើកបរយាន អ្នកថ្មើរជើង អ្នកធ្វើអាជីវកម្មលើផ្លូវថ្នល់ អ្នកឃ្វាលឬអ្នកប្រើប្រាស់សត្វពាហនៈនិងអ្នកប្រើប្រាស់ផ្លូវថ្នល់ក្នុងគោលបំណងផ្សេងទៀត។

# ឯកសារឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១ ប្លង់ព្រំប្រទល់រដ្ឋបាលខណ្ឌសែនសុខ



ឧបសម្ព័ន្ធទី២ ប្លង់បណ្ដាញផ្លូវថ្នល់និងគមនាគមន៍ចម្បងៗ



# ឧបសម្ព័ន្ធទី៣ ប្លង់កំណត់កម្ពស់សំណង់តាមវិថីសំខាន់ៗ



# ឧបសម្ព័ន្ធទី៤ ប្លង់កំណត់កម្ពស់សំណង់តាមសន្ទស្សន៍ប្រើប្រាស់ដី



# ឧបសម្ព័ន្ធទី៥ ប្លង់កំណត់កម្ពស់សំណង់ក្នុងតំបន់គ្រប់គ្រងកម្ពស់ឧបសគ្គ




កម្ពស់សំណង់ក្នុងរាជធានីភ្នំពេញដែលបានកំណត់កម្ពស់ជាម៉ែត្រនិងកំណត់កម្ពស់តាមសន្ទស្សន៍ប្រើប្រាស់ដីដែលស្ថិតនៅក្នុងតំបន់គ្រប់គ្រងកម្ពស់ឧបសគ្គត្រូវមានកម្ពស់ទាបជាងដាច់ខាតនៃការកំណត់កម្ពស់ឧបសគ្គសម្រាប់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

# ឧបសម្ព័ន្ធទី៦ ប្លង់លម្ហសាធារណៈនិងផ្ទៃបៃតង



## ឧបសម្ព័ន្ធទី៧ គំរូចិញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងផ្លូវទោចក្រយានសម្រាប់សាធារណជននិងជនពិការ




## ឧបសម្ព័ន្ធទី៨ ប្លង់ពុះកាត់ផ្លូវលេខ១៩២៨



## ឧបសម្ព័ន្ធទី៩ ប្លង់ពុះកាត់ផ្លូវលេខ១០១៩




## ឧបសម្ព័ន្ធទី១០ ប្លង់ពុះកាត់ផ្លូវលេខ២០០៤

គំរូជាក់ស្តែង : ចញ្ចើមផ្លូវ ផ្លូវថ្មើរជើង និងគន្លងយានយន្ត






## ឧបសម្ព័ន្ធទី១១ ប្លង់ពុះកាត់តំបន់លំនៅឋានក្នុងសហគមន៍សំរោងមានជ័យក្នុងសង្កាត់ឃ្មួញ



## ឧបសម្ព័ន្ធទី១២ ប្លង់ពុះកាត់ប្រឡាយអូរអាគុជស្ថិតនៅក្នុងសង្កាត់ភ្នំពេញថ្មី



## ឧបសម្ព័ន្ធទី១៣ ប្លង់អាងបង្គន់អនាម័យនិងអាងប្រព្រឹត្តកម្មទឹកកខ្វក់

អាងបង្គន់អនាម័យសំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យនិងបន្ទប់ទឹកដើម្បីស្តុកនិងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់មុននឹងបង្ហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ។ បទដ្ឋានអាងបង្គន់អនាម័យត្រូវបានកំណត់ដូចតទៅ៖

- ទំហំប្រើប្រាស់នៃអាងបង្គន់អនាម័យដោយគិតពីបាតអាងឡើងមកដល់បំពង់បង្ហូរចេញជាអប្បបរមា ៣ម៉ែត្រត្រីគុណសម្រាប់លំនៅឋាន៣ម៉ែត្រត្រីគុណក្នុងមួយជាន់នៃផ្ទះល្វែង ឬនៃភូមិគ្រឹះ៣ម៉ែត្រត្រីគុណសម្រាប់ផ្ទៃក្រឡាកម្រាលសរុប៨០ម៉ែត្រទ្វេរគុណ
- សណ្ឋាគារឬផ្ទះសំណាក់២ម៉ែត្រត្រីគុណបូកបន្ថែម០,៥០ម៉ែត្រត្រីគុណក្នុងមួយបន្ទប់
- កម្ពស់អាងបង្គន់អនាម័យពុំអាចទាបជាង១,៥០ម៉ែត្រ
- អាងបង្គន់អនាម័យត្រូវមានរន្ធបង្ហុយខ្ពស់ទៅលើ
- មិនត្រូវឱ្យទឹកភ្លៀងហូរចូលក្នុងអាងបង្គន់អនាម័យជាដាច់ខាត។




ប្លង់អាងបង្គន់អនាម័យ

ចំពោះរោងចក្រ សហគ្រាស សិប្បកម្ម និងបុរីទាំងអស់ត្រូវម្ចាស់ការក្នុងការរៀបចំនិងបំពាក់នូវអាងប្រព្រឹត្តកម្មទឹកកខ្វក់ដើម្បីសម្អាតសំណល់រាវដែលចេញពីរោងចក្រ សហគ្រាស សិប្បកម្ម និងបុរីទាំងនេះឱ្យស្របតាមបទដ្ឋានបច្ចេកទេសមុននឹងបង្ហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ។ ប្លង់គំរូអាងប្រព្រឹត្តកម្មទឹកកខ្វក់សម្រាប់សំណង់ឧស្សាហកម្មឬសំណង់ដែលមានសំណល់សរីរាង្គឬជាតិពុល។






ប្លង់ពុះ ក_ក




ប្លង់គម្រូអាងប្រព្រឹត្តកម្មកាកសំណល់រាវ

ឧបសម្ព័ន្ធទី១៤ ការកំណត់លេខផ្លូវនិងលេខផ្ទះ



ឧទាហរណ៍: ការដាក់ផ្លូវ និងលេខផ្ទះ ឬដីឡូត៍ ពីជើងមកត្បូង ពីកើតមកលិច

## ក- ការដាក់លេខផ្លូវនូវលេខគូនិងលេខសេស




គំនូសបង្ហាញការដាក់លេខផ្លូវ

- ការដាក់លេខផ្លូវដោយប្រើលេខគូគឺអនុវត្តចាប់ពីទិសខាងជើងមកទិសខាងត្បូងតាមលំដាប់ពីតូចមកធំ។ ផ្លូវលេខគូគឺជាផ្លូវដែលសណ្តូកពីទិសខាងកើតមកទិសខាងលិចឬចន្លោះទិសខាងកើត-ឦសានទៅទិសខាងលិច-នីរតីឬចន្លោះពីទិសខាងកើត-អាគ្នេយ៍ទៅទិសខាងលិច-ពាយ័ព្យ
- ការដាក់លេខផ្លូវដោយប្រើលេខសេសគឺអនុវត្តចាប់ពីទិសខាងកើតមកទិសខាងលិចតាមលំដាប់ពីតូចមកធំ។ ផ្លូវលេខសេសគឺជាផ្លូវដែលសណ្តូកពីទិសខាងជើងមកទិសខាងត្បូងឬចន្លោះពីទិសខាងជើង-ឦសានទៅទិសខាងត្បូង-នីរតីឬចន្លោះពីទិសខាងជើង-ពាយ័ព្យទៅទិសខាងត្បូង-អាគ្នេយ៍។

ក្នុងករណីផ្លូវកាត់សណ្តូកក្នុងទិសផ្លូវលេខគូនិងផ្លូវលេខសេសផងត្រូវកំណត់យកលេខគូឬលេខសេសតាមលេខផ្លូវណាដែលមានភាគរយផ្លូវស្ថិតនៅច្រើនជាង។

ចំពោះលេខផ្លូវដែលដាក់តាមលំដាប់លេខរៀង ហើយត្រូវកាត់ផ្តាច់ដោយបរិក្ខារសាធារណៈឬធាតុធម្មជាតិមិនអាចឆ្លងកាត់បានត្រូវប្រើលេខបន្តបន្ទាប់តាមលំដាប់លេខរៀង។

ការដាក់ឈ្មោះផ្លូវដោយដាក់ឈ្មោះរបស់អ្នកមានស្នាដៃជូនជាតិ វិរៈជនជាតិនិងអន្តរជាតិត្រូវអនុលោមតាមការអនុញ្ញាតដោយច្បាប់។

ការដាក់លេខផ្លូវត្រូវធ្វើសមាហរណកម្មទៅនឹងតំបន់ជាប់ព្រំប្រទល់ខណ្ឌតាមលេខរៀងលំដាប់តៗគ្នា។

ខ-ការដាក់លេខផ្ទះ




**គំនូសបង្ហាញការដាក់លេខផ្ទះឬដីឡូត៍ពីជើងមកត្បូង**




**គំនូសបង្ហាញការដាក់លេខផ្ទះឬដីឡូត៍ពីកើតមកលិច**

ការដាក់លេខផ្ទះគឺអនុវត្តពីទិសខាងជើងមកទិសខាងត្បូងនិងពីទិសខាងកើតមកទិសខាងលិច ហើយចាប់ផ្តើមដាក់លេខពីដើមទីនៃផ្លូវលេខរហូតដល់ចុងទីនៃផ្លូវលេខនីមួយៗ។

នៅពេលដែលមនុស្សឈរបែរមុខទៅទិសខាងជើងនៅលើបណ្តោយផ្លូវដែលមានលេខសេសៈ

- នៅខាងស្តាំដៃពីជើងមកត្បូងគឺជាលេខគូ ហើយការដាក់លេខផ្ទះឬដីឡូត៍ត្រូវអនុវត្តតាមលំដាប់លេខរៀងពីតូចមកធំ
- នៅខាងឆ្វេងដៃពីជើងមកត្បូងគឺជាលេខសេស ហើយការដាក់លេខផ្ទះឬដីឡូត៍ត្រូវអនុវត្តតាមលំដាប់លេខរៀងពីតូចមកធំ។

នៅពេលដែលមនុស្សឈរបែរមុខទៅទិសខាងកើតនៅលើបណ្តោយផ្លូវដែលមានលេខគូៈ

- នៅខាងស្តាំដៃពីកើតមកលិចគឺជាលេខគូ ហើយការដាក់លេខផ្ទះឬដីឡូត៍ត្រូវអនុវត្តតាមលំដាប់លេខរៀងពីតូចមកធំ។ ការដាក់លេខផ្ទះឬដីឡូត៍មកដល់ផ្លូវកែងលេខសេសត្រូវរំលងចំនួនពីរផ្ទះឬពីរដីឡូត៍នៅខាងកើតនិងខាងលិចផ្លូវដែលមានលេខសេស ទើបអនុវត្តការដាក់លេខរៀងបន្តពីតូចទៅធំទៀត ព្រោះផ្ទះឬដីឡូត៍នៅផ្លូវកែងនេះមានលំដាប់លេខរៀងពីជើងមកត្បូងរួចហើយ
- នៅខាងឆ្វេងដៃពីកើតមកលិចគឺជាលេខសេស ហើយការដាក់លេខផ្ទះឬដីឡូត៍អនុវត្តតាមលំដាប់លេខរៀងពីតូចមកធំ។ ការដាក់លេខផ្ទះឬដីឡូត៍មកដល់ផ្លូវកែងលេខសេសត្រូវរំលងចំនួនពីរផ្ទះឬពីរដីឡូត៍នៅខាងកើតនិងខាងលិចផ្លូវដែលមានលេខសេស ទើបអនុវត្តការដាក់លេខរៀងបន្តពីតូចទៅធំទៀត ព្រោះផ្ទះឬដីឡូត៍នៅផ្លូវកែងនេះមានលំដាប់លេខរៀងពីជើងមកត្បូងរួចហើយ។

ការដាក់លេខផ្ទះឬដីឡូត៍នេះត្រូវធ្វើសមាហរណកម្មនឹងតំបន់ជាប់ព្រំប្រទល់ខណ្ឌនិងមានលំដាប់លេខរៀងបន្តបន្ទាប់គ្នា។

ចំពោះដីឡូត៍ដែលមានលេខរួច ហើយដីឡូត៍នោះត្រូវធ្វើការសាងសង់ផ្ទះឬពុះជាច្រើនឡូត៍បន្តទៀត ការដាក់លេខផ្ទះឬដីឡូត៍ត្រូវអនុវត្តការដាក់ឈ្មោះលេខដើមដោយបន្ថែមអក្សរឡាតាំងតាមលំដាប់ពីតួអក្សរដំបូងបន្តបន្ទាប់តាមទិសពីជើងទៅត្បូងនិងពីកើតទៅលិច។

# ឧបសម្ព័ន្ធទី១៥ តំបន់ប្រើប្រាស់ដី កម្ពស់សំណង់ និងប្រភេទសំណង់

| តំបន់ប្រើប្រាស់ដី និងកម្ពស់សំណង់ | សន្ទស្សន៍ប្រើប្រាស់ដី | ផលធៀបក្រឡាផ្ទៃបាតសំណង់ | ប្រភេទសំណង់ | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | អគារលំនៅឋាន (ភូមិគ្រឹះ និងពាក់កណ្ដាលភូមិគ្រឹះ) | អគារលំនៅឋាន (ល្វែង និងផ្ទះជាប់គ្នា) | អគារលំនៅឋាន (អគារស្នាក់នៅរួម) | អគារពាណិជ្ជកម្ម (ភោជនីយដ្ឋាន) | អគារពាណិជ្ជកម្ម (ភេសជ្ជដ្ឋាន) | អគារពាណិជ្ជកម្ម (ផ្សារទំនើប) | អគារពាណិជ្ជកម្ម (ស្តុកទំនិញ) | អគារពាណិជ្ជកម្ម (ការិយាល័យ) | អគារឧស្សាហកម្ម (រោងចក្រ) | អគារឧស្សាហកម្ម (ឃ្លាំង) | អគារសិក្សាធិការ អប់រំ និងកីឡា | អគារសុខភាព (មន្ទីរពេទ្យ) | អគារសុខភាព (គ្លីនិកពេទ្យ) | អគារសាលមហោស្រព សាលប្រជុំ និងអគារកម្សាន្ត | សណ្ឋាគារ ផ្ទះសំណាក់ | ការិយាល័យរដ្ឋបាល | ការិយាល័យឯកជន | ស្ថានីយប្រេងឥន្ធនៈ | អគារចំណតយានយន្ត | អគារផ្សេងៗ |
| **ការកំណត់កម្ពស់សំណង់តាមសន្ទស្សន៍ប្រើប្រាស់ដី** | | | | | | | | | | | | | | | | | | | | | | |
| ក. ប្រភេទដីអាចសាងសង់បាន | | | | | | | | | | | | | | | | | | | | | | |
| ១. តំបន់លំនៅឋាន | | | | | | | | | | | | | | | | | | | | | | |
| ១.១ តំបន់លំនៅឋានដាច់ពីគ្នាកម្ពស់ទាប | FAR≤1.5 | BCR≤50% | ✓ | | | | | | | | | | | | | | | | | | | ✓ |
| ១.២ តំបន់លំនៅឋានជាប់គ្នាកម្ពស់ទាប | FAR≤1.5 | BCR≤75% | ✓ | ✓ | ✓ | | | | | | | | | | | | | | | | | ✓ |
| ១.៣ តំបន់លំនៅឋានកម្ពស់មធ្យមប្រភេទ១ | FAR≤3.0 | BCR≤60% | ✓ | ✓ | ✓ | | ✓ | | | ✓ | | | ✓ | ✓ | | | | | | | ✓ | ✓ |
| ១.៤ តំបន់លំនៅឋានកម្ពស់មធ្យមប្រភេទ២ | FAR≤3.0 | BCR≤60% | ✓ | ✓ | ✓ | | ✓ | | | ✓ | | | ✓ | ✓ | | | | | | | ✓ | ✓ |
| ១.៥ តំបន់លំនៅឋានកម្ពស់ខ្ពស់ប្រភេទ១ | FAR≤5.0 | BCR≤60% | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | | | ✓ | ✓ | | | | | | | ✓ | ✓ |
| ១.៦ តំបន់លំនៅឋានកម្ពស់ខ្ពស់ប្រភេទ២ | FAR≤5.0 | BCR≤60% | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | | | ✓ | ✓ | | | | | | | ✓ | ✓ |
| ១.៧ តំបន់លំនៅឋានចម្រុះ | FAR≤5.0 | BCR≤65% | ✓ | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | | | ✓ | ✓ | | | | | | | ✓ | ✓ |
| ២. តំបន់ពាណិជ្ជកម្ម | | | | | | | | | | | | | | | | | | | | | | |
| ២.១. តំបន់ពាណិជ្ជកម្ម | FAR≤12 | BCR≤75% | | | | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ |
| ២.២. តំបន់ពាណិជ្ជកម្មចម្រុះ | FAR≤10 | BCR≤70% | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ |
| ៣. តំបន់ឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | |
| ៣.១. តំបន់ឧស្សាហកម្ម | FAR≤3.0 | BCR≤60% | | | | | | | | | ✓ | ✓ | | | | | | | | | | △ |
| ៣.២. តំបន់ឧស្សាហកម្មស្រាល | FAR≤3.0 | BCR≤60% | ✓ | ✓ | ✓ | | | | | | ✓ | ✓ | | | | | | | | | | △ |
| ៣.៣. តំបន់ឧស្សាហកម្មចម្រុះ | FAR≤3.0 | BCR≤60% | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | △ |
| ៤. តំបន់ចម្រុះ | FAR≤10 | BCR≤70% | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ |
| ៥. តំបន់ដឹកជញ្ជូន | FAR≤3.0 | BCR≤60% | | | | | | | | | | | | | | | | | ✓ | | | ✓ |
| ៦. តំបន់ទេសចរណ៍ | FAR≤5.0 | BCR≤50% | | | | ✓ | ✓ | ✓ | | ✓ | | | | | ✓ | | ✓ | | | | | ✓ |
| ៧. តំបន់រដ្ឋបាល និងសេវាសាធារណៈ | FAR≤5.0 | BCR≤60% | | | | | | | | ✓ | | | ✓ | ✓ | ✓ | | | ✓ | ✓ | | | ✓ |
| ៨. តំបន់លំហសាធារណៈ និងផ្ទៃបៃតង | FAR≤0.3 | BCR≤10% | | | | | | | | | | | | | | | | | | | | ✓ |
| ៩. តំបន់វប្បធម៌ និងសាសនា | FAR≤2.0 | BCR≤50% | | | | | | | | | | | ✓ | | | | | | | | | △ |
| ១០. តំបន់ផ្សេងៗ | FAR≤5.0 | BCR≤50% | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ | △ |
| ខ. ប្រភេទដីកម្រិតការសាងសង់ | | | | | | | | | | | | | | | | | | | | | | |
| ១. តំបន់កសិកម្ម (ស្រែ ចំការ កសិដ្ឋាន ដំណាំក្នុងភូមិ) | FAR≤1.5 | BCR≤30% | | | | | | | | | | | | | | | | | | | | ✓ |
| ២. តំបន់ព្រៃឈើ (ព្រៃបំរុងទុកអចិន្ត្រៃយ៍ ព្រៃឯកជន ព្រៃលិចទឹក) | | | | | | | | | | | | | | | | | | | | | | ✓ |
| ៣. តំបន់ធនធានទឹក | | | | | | | | | | | | | | | | | | | | | | ✓ |
| ៤. តំបន់ការពារ | | | | | | | | | | | | | | | | | | | | | | |
| ៥. តំបន់ផ្សេងៗកម្រិតការសាងសង់ | | | | | | | | | | | | | | | | | | | | | | ✓ |

**កម្ពស់អគារមានកម្រិត**

- កម្ពស់ចាប់ពីជាន់ទី៩ ដល់ជាន់ទី១១
- កម្ពស់ចាប់ពីជាន់ទី១២ឡើងទៅ

**សម្គាល់**

✈ ការសាងសង់សំណង់ខ្ពស់ៗគ្រប់ប្រភេទ នៅក្នុងតំបន់គ្រប់គ្រងកម្ពស់ឧបសគ្គ ត្រូវអនុវត្តតាមលិខិតលេខ០០៤១ ស.ណ.អ.ស ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១០ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

✓ អនុញ្ញាតឲ្យសាងសង់ △ មានលក្ខខណ្ឌ

**ចម្ងាយអគារខ្ពស់ពីព្រំដីឡូត៍ពីព្រំដីគាត់តាមស្របច្បាប់**

| ល.រ. | អគារដែលមានកម្ពស់ | គម្លាតពីព្រំដីចំណីផ្លូវ(ម៉ែត្រ) | គម្លាតមិនជាប់ព្រំដីចំណីផ្លូវ(ម៉ែត្រ) | ផ្សេងៗ |
|---|---|---|---|---|
| ១. | ចាប់ពីជាន់ផ្ទាល់ដី ដល់ជាន់ទី៨ | ≥ 4.00 | ≥ 2.00 | |
| ២. | ចាប់ពីជាន់ទី៩ ដល់ជាន់ទី១១ | ≥ 5.00 | ≥ 2.50 | |
| ៣. | ចាប់ពីជាន់ទី១២ ឡើងទៅ | > 5.00 | > 2.50 | |
| ៤. | ចាប់ពីជាន់ទី១២ ដល់ជាន់ទី២០ | ≥ 6.00 | ≥ 3.00 | សម្រាប់សំណង់ស្ថិតតាមបណ្ដោយមហាវិថី |
| ៥. | ចាប់ពីជាន់ទី ២១ ដល់ជាន់ទី៣០ | ≥ 8.00 | ≥ 3.50 | សម្រាប់សំណង់ស្ថិតតាមបណ្ដោយមហាវិថី |
| ៦. | ចាប់ពីជាន់ទី ៣១ ឡើងទៅ | ≥ 10.00 | ≥ 4.00 | សម្រាប់សំណង់ស្ថិតតាមបណ្ដោយមហាវិថី |

## ឧបសម្ព័ន្ធទី១៦ ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ ចក្ខុវិស័យឆ្នាំ២០៣៥



ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ថ្នាក់ជាតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានីភ្នំពេញ
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម រាជធានីភ្នំពេញ

# ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខនៃរាជធានីភ្នំពេញ ចក្ខុវិស័យឆ្នាំ២០៣៥




ផែនទីព្រះរាជាណាចក្រកម្ពុជា

ផែនទីរដ្ឋបាលរាជធានីភ្នំពេញ

មាត្រដ្ឋានផែនទី

មាត្រដ្ឋាន ១/៣០០០០

COORDINATE SYSTEM: WGS_1984_UTM_Zone_48N

# ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ

## ចក្ខុវិស័យឆ្នាំ ២០៣៥




រៀបចំដោយ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

អាសយដ្ឋានៈ ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរសព្ទ/ទូរសារ (៨៥៥) ២៣ ២១៥ ៦៦០ / ២៣ ២១៥ ២៧៧

គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabitnet!gmail.com


ប្លង់គោលប្រើប្រាស់ដីខណ្ឌសែនសុខ ចក្ខុវិស័យឆ្នាំ ២០៣៥